ព្រះពុទ្ធសាសនា

# ធម៌
# នមស្ការព្រះរតនត្រៃ

## សម្រាប់
## ពុទ្ធបរិស័ទ មិនទាន់ចេះសូត្រ

ចងក្រងដោយ

**ឧបាសិកា វ៉ាន់ លុយ**

ព.ស.២៥៥៦ គ.ស.២០១៣

សម្រាប់ចម្លងចែកជាធម្មទាន

ទឹកពិសា EUROTECH®

INTERNATIONAL STANDARD QUALIFIED - ISO 9001:2008




សេវាដឹកជញ្ជូន 011 707 555 - 012 707 555
015 707 555 - 069 707 555

# អារម្ភកថា

ព្រះពុទ្ធជាម្ចាស់ បានបង្រៀនមនុស្សអោយជឿលើកម្ម និងផល។ កម្ម ដែលបុគ្គលជាអ្នកសាង រមែងទទួលនូវផលនោះវិញជាមិនខាន ។ អ្វីៗកើតឡើងព្រោះហេតុ និងផល ព្រោះតែហេតុដែលបុគ្គលជាអ្នកធ្វើ ទើបទទួលបាននូវផលនោះវិញ ។ នាងខ្ញុំមានជំនឿយ៉ាងខ្លាំងលើកម្ម និងផល ជាពិសេសបានឃើញយ៉ាងច្បាស់នូវគុណតម្លៃ ដែលមិនអាចកាត់ថ្លៃបានរបស់ព្រះពុទ្ធជាម្ចាស់ ដែលព្រះអង្គទ្រង់ទេសនាបង្ហាញនូវផ្លូវត្រូវ ដល់មនុស្សគ្រប់វណ្ណៈ។ ព្រះពុទ្ធ គឺជាតួអង្គយ៉ាងសំខាន់ ក្នុងការកែប្រែនូវទង្វើរបស់មនុស្ស នឹងជាអ្នកបង្ហាញនូវមាគ៌ាដ៏ល្អ សម្រាប់សកម្មភាពទាំងឡាយរបស់មនុស្ស ទ្រង់ប្រៀនប្រដៅអោយមានការជឿជាក់លើខ្លួនឯង និងខ្លួនទីពឹងខ្លួន ដោយខ្លួនជាអ្នកអោយសុខដល់ខ្លួនឯង ។ នាងខ្ញុំស្រឡាញ់គោរពលើព្រះពុទ្ធសាសនា នឹងចង់រក្សានូវតម្លៃព្រះពុទ្ធសាសនាឱ្យគង់វង្ស។ អាស្រ័យហេតុដូច្នេះហើយ ទើបជំរុញចិត្តនាងខ្ញុំអោយខិតខំប្រមូលនូវធម៌មនស្សការ ពីសៀវភៅធម៌ផ្សេងៗ មករៀបរៀងដាក់បញ្ចូលជាសៀវភៅធម៌នេះ ដើម្បីទុកជាប្រយោជន៍ដល់ព្រះពុទ្ធសាសនា។ ម្យ៉ាងទៀត ដោយមើលឃើញពីផលវិបាករបស់ពុទ្ធបរិស័ទសម័យបច្ចុប្បន្ន ភាគច្រើនមិនទាន់ចេះអានអក្សរបាលី ទើបមិនចង់រៀនធម៌។ ហេតុនេះ ទើបនាងខ្ញុំបានផ្តួចផ្តើមគំនិត រៀបរៀងសៀវភៅធម៌ ដោយមានសរសេរពាក្យសម្រាយខាងក្រោម ដើម្បីងាយស្រួលក្នុងការអាន ហើយបានរៀបចំវាយកុំព្យូទ័រដោយក្លួយ **ទ្រី សុធី** រហូតដល់ចប់ ទើបយកទៅប្រគេនព្រះតេជគុណ

២

**ធម្មបាល រិត សោរង្សី** គង់នៅវត្តឧណ្ណាលោម ជួយពិនិត្យកែតម្រូវលើអក្ខរាវិរុទ្ធ និងខ្លឹមសារនៃធម៌។

នាងខ្ញុំជឿជាក់ថាកំហុសឆ្គងពិតជាមានដោយអចេតនា អាស្រ័យហេតុនេះ សូមព្រះករុណាគ្រប់ព្រះអង្គ ព្រមទាំងពុទ្ធបរិស័ទទាំងអស់មេត្តាជួយកែតម្រូវ នាងខ្ញុំរីករាយទទួលដោយសោមនស្ស ដើម្បីជាប្រយោជន៏តម្កល់ទុកក្នុងព្រះពុទ្ធសាសនា។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពឧទ្ទិសដល់វិញ្ញាណក្ខន្ធ លោកអ្នកដ៏មានគុណមានមាតាបិតា ព្រមទាំងញាតិកាទាំងប្រាំពីរសន្តាន សូមមកទទួលនូវបុណ្យកុសលដែលកើតឡើងពីធម្មទាននេះដោយរីករាយ។ មួយអន្លើ សូមឧទ្ទិសជូនដល់វិញ្ញាណក្ខន្ធ អស់លោកអ្នកប្រាជ្ញ កវី បណ្ឌិត ដែលបានរួមចំណែកថែរក្សាព្រះពុទ្ធសាសនា សូមអស់លោកអ្នកទាំងនោះ ទទួលអនុមោទនានូវបុណ្យដែលកើតឡើងពីធម្មទាន ដែលនាងខ្ញុំខិតខំរៀបរៀងសៀវភៅធម៌នមស្សការនេះផងចុះ។ ជាពិសេស សូមគោរពជូនពរដល់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទទាំងអស់ ដែលកំពុងរស់នៅសព្វថ្ងៃ សូមទទួលបាននូវសុខភាពល្អប្រាជ្ញាឈ្លាសវៃ ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនាឱ្យគ្រប់ប្រាំពាន់ព្រះវស្សាទៅហោង ។ **សូមអនុមោទនា!**

ថ្ងៃ សុក្រ ១៥កើត ខែ អាសាឍ ត្រូវនឹងថ្ងៃទី ១៥ ខែ កក្កដា ព. ស. ២៥៥៥ / គ. ស. ២០១១

**ឧបាសិកា ទ៉ាន់ ល្មុយ**

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**


១- បទសរភញ្ញ និងនមស្ការ ............ ១
២- បទសូធ្យលើកទង់ព្រះពុទ្ធសាសនា ............ ២
៣- កំណើតឆព្វណ្ណរង្សី ............ ៤
៤- ធម៌ថ្វាយបង្គំព្រះពុទ្ធប្រាំព្រះអង្គ ............ ៥
៥- រតនបូជា ............ ៦
៦- ពុទ្ធរតនប្បណាម ............ ៧
៧- ធម្មរតនប្បណាម ............ ១០
៨- សង្ឃរតនប្បណាម ............ ១៤
៩- យោកប្បកោដី ............ ១៩
១០- ថ្វាយបង្គំសុំសេចក្ដីសុខ ............ ២១
១១- នមស្ការបូជនីយវត្ថុជាទីគោរព ............ ២២
១២- នមស្ការព្រះពុទ្ធបាទ ............ ២៣
១៣-វិធីសមាទានសីល ៥ (និច្ចសីល) ............ ២៦

១៤- វិធីសមាទានឧបោសថសីល ........ ៣១

១៥- បត្តិទានគាថា ........ ៣៥

១៦- ឧទ្ទិសកុសលជាពាក្យកាព្យ ........ ៣៧

១៧- ធម៌ឧទ្ទិសផល ........ ៣៨

១៨- ធម៌ឧទ្ទិសសង្ខេប ........ ៣៩

១៩-បាលីវេរសង្ឃទាន........ ៣៩

២១- ផ្សាយមេត្តាចំពោះសព្វសត្វទាំង ១០ ទិស ........ ៤០

២២- សុភមង្គលគាថា ........ ៤៣

២៣- បរិត្តភាសនាយាចនគាថា ........ ៤៤

២៤- ធម៌សូធ្យសុំសេចក្តីសុខ ........ ៤៤

២៣- បត្តិទានគាថា ........ ៤៦

២៤- ធម៌ឧទ្ទិសទាន ........ ៤៩

២៥- ធម៌សម្រាប់សូធ្យឧទ្ទិសផល ........ ៥០

២៦- តេជះខ្ញុំសាង ........ ៥១

២៧- គោតមប្រវត្តិ ........ ៥២

២៨- ធម៌សូធ្យឧទ្ទិសបុណ្យ ........ ៥៤

២៩- ពាក្យសូមប្រាថ្នា ........................................ ៥៥
៣០- ពុទ្ធកិច្ច ៥ យ៉ាង ........................................ ៥៦
៣១- ធម្មនិយាម ៣០ របស់ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ ........ ៥៧
៣២- ការក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ តាំង នមោ ៣ ចប់ ........ ៦២
៣៣- ធម៌សម្រាប់ប្រោះទឹកស្មោទក់ ........................................ ៦៣
៣៤- មង្គល ៣៨ ប្រការ ........................................ ៦៦
៣៥- បរាភវសូត្រ ........................................ ៧១

## អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ

-ភិក្ខុ ធម្មផាសុកត្ថេរោ **ផល សុផា** ព្រះចៅអធិការវត្តអង្គស្គុក សង្កាត់ ឪឡោក ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ

- ភិក្ខុធម្មបាល **រ៉ិត សោរខឿ**
- លោកឪពុក **ហ៊ុខ ឡៀខ**
- ឧបាសក **ឡៀខ ថៃ**
- លោក **ឡើ សុធី** (អ្នកវាយកុំព្យូទ័រ)
- លោក **សុន្ទ័រ សាមឿន**

# បទសរភញ្ញ និងនមស្ការ

សូមថ្វាយបង្គំព្រះសម្ពុទ្ធ    ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេវតា    ទ្រង់ត្រាស់ទេសនាប្រដៅសត្វ
ចង្អុលឱ្យដើរផ្លូវកណ្ដាល    មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឱ្យខ្ចាយបាត់    អាចកាត់សង្សារៈទុក្ខបាន ។
សាសនាព្រះអង្គនៅសព្វថ្ងៃ    សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់ចេះចាំបាន    កាន់តាមលំអានបានក្ដីសុខ
ឥតមានសុខណាស្មើក្ដីស្ងប់    បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ    ក្ដីសុខនឹងមានព្រោះធម៌ស្ងប់ ។
ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌    ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរតន៍គួរគោរព    ជាម្លប់ត្រជាក់នៃលោកា
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ    វិសុទ្ធតាងអង្គព្រះសាស្ដា
សូមគុណត្រៃរតន៍ជួយខេមរា    ឱ្យបានសុខាតរៀងទៅ ។

*( ក្រាបថ្វាយបង្គំម្ដង)*

**សម្ដេចព្រះសង្ឃរាជ ជួន ណាត ( ជោតញ្ញាណោ)**

**នត្ថិ សន្តិ បរំ សុខំ**

សុខដទៃក្រៅពីសេចក្ដីស្ងប់មិនមានឡើយ

# បទស្មូត្រលើកតម្កើងព្រះពុទ្ធសាសនា

១. សូមមើលទង់ជ័យ ឆព្វណ្ណរង្សី
ដែលមានរស្មី ភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស
ហង្សបាទនិងពណ៌ ដ៏ភ្លឺផ្លេក ។

២. ប្រទេសតូចធំ បានស្ម័គ្រស្វាគម
ជំនុំគ្នាច្រើន អនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក
ប្រសើរពន់ពេក ក្រៃកន្លង ។

៣. ធ្វើជាសញ្ញា ទង់ជ័យសាសនា
នៃព្រះសម្ពុទ្ធធំចម្បង ចូរយើងរាល់គ្នា
យកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់ ។

៤. ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា
សុទ្ធសឹងតែជា ពុទ្ធសាសនិ៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់
ប្រឹងប្រែងឱ្យណាស់ គ្រប់ៗគ្នា ។

៥. សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត

រុងរឿងវិសុទ្ធ ថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា
ដោយជនជ្រះថ្លា ច្រើនសែនលាន ។

៦. មានចិត្តស្នេហា គោរពបូជា
ចំពោះព្រះធម៌ ដ៏កល្យាណ
ទាំងមនុស្សទេព្តា ស្នេហាគ្រប់ប្រាណ
ប្រាថ្នាចង់បាន សេចក្តីសុខ

៧. យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត
កាន់ធម៌នឹងបាន ផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ
យើងនឹងបានសុខ ក្សេមក្សាន្តត្រាណ ។

៨. ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត
ឆ្ពោះទៅកាន់ឋាន និព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត
ជាតិយើងនឹងបាន សោយសុខា ។

# កំណើតឆព្វណ្ណរង្សី

១. ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។

២. ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរុងប្រសើរបវរ
ឆ្មៀលឆ្វាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។

៣. កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវ៉ា
ធ្វើទានឥតមានរុញរា កាលដែលនៅជាព្រះពោធិសត្វ ។

៤. រស្មីពណ៌ខៀវនោះណា កាលឆ្មៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីភិរាស្ត្រ ។

៥. រស្មីពណ៌លឿងនោះណា កាលដែលទ្រង់អារសាច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទជាងមាសទ្រង់វីយបណ្ឌិត ។

៦. រស្មី ក្រហមនោះណា កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត កាត់បេះដូងបិទធ្វើថ្នាំមាតា ។

៧. រស្មី ពណ៌សសុទ្ធសាធ កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឱ្យដីរសសោភា ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ ។

៨. រស្មី ពណ៌ដូចជើងហង្ស កាលមាតាទ្រង់យក្ខចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ ឱ្យយក្ខសាមាន្យស៊ីប្តូរជីវិត ។

៩. រស្មី ភ្លឺផ្លេកពណ៌ព្រាយ កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ ។
១០. រស្មីខៀវលឿងក្រហម សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ទាំងចាស់កុមារចូរចាំទុកអើយ ។

## ធម៌ថ្វាយបង្គំព្រះពុទ្ធប្រាំព្រះអង្គ

**ឧកាស** ខ្ញុំសូមវន្ទា នូវព្រះឈ្នះមារ ទាំងប្រាំព្រះអង្គ
សូមយាងបារមី ម្ចាស់ថ្លៃមកគង់ នៅនាកំឡុង ។
ទីស្ថាននេះណា ព្រះកកុសន្ធោ ព្រះកោនាគមនោ
ព្រះកស្សបោ ព្រះសមណគោតម បរមពុទ្ធោ ។
ព្រះមេត្តេយ្យោ ព្រះពោធិសត្វថ្លៃ ព្រមទាំងព្រះធម៌
ជ្រាលជ្រៅបវរ ប្រសើរពេកក្រៃ ប្រាំបីម៉ឺនបួនពាន់
ព្រះធម្មក្ខន្ធនេះនៃ របស់ព្រះជិនស្រី ទីទៃវាល់អង្គ
ព្រមទាំងព្រះសង្ឃ ប្រសើរសីលទ្រង់ ជាបុត្រព្រះពុទ្ធ
លះកាត់តណ្ហា ប្រសើរបំផុត ខ្ញុំសូមលំអុត
កាយវាចាចិត្ត ដោយតេជះខ្ញុំ លើកហត្ថបង្គំ
ត្រៃរតនា សូមកម្ចាត់បង់ សត្រូវនានា
ទុក្ខសោករោគា វិនាសទៅហោង ។

# រតនបូជា

**(ការបូជាគ្រឿងសក្ការៈដល់ព្រះរតនត្រៃ)**

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ**

(អ៊ិម៉េហិ ទីប៉ាក់ធូប៉ាទិសាក់ការេហិ ពុទធាំង ធ័មមាំង សាំងឃាំង)

**អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច**

( អភិប៉ូជាក់យាមិ មាតាបិុតាទីនាំង គុណាក់វ៉ាន់តាណាញ់ចាក់ )

**មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ៕**

( ម៉ៃហាញ់ចាក់ ទីឃាក់រ័តតាំង អាត់ថាយាក់ ហិតាយាក់ សុខាយាក់)

**ប្រែថា** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀននិងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់អ្នកដ៏មានគុណទាំង-ឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៕**

(នាក់មោ តាស់សាក់ ភាគ់គាក់វ៉ាក់តោ អាក់រ៉ាក់ហាក់តោ សាំម៉ាសាំពុទធាស់សាក់)

***(សូត្រ៣ចប់)***

**ប្រែ** វីកិរិយានមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

# ពុទ្ធរតនប្បណាម

**យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំ**

(យោ សាន់ណិសិនណោ វ៉ាក់រាក់ពោធិមូលេ មារាំង សាក់សេណាំង)

**មហតឹ វិជេយ្យោ សម្ពោធិមាគច្ឆិ អនន្តញ្ញាណោ**

(មាក់ហាក់តឹង វិជៃយោ សាំពោធិមាគាច់ឆិ អាក់ណាន់តាញ៉ូញ៉ាណោ)

**លោកុត្តមោ តំ បនមាមិ ពុទ្ធំ**

(លោកុតតាក់ម៉ោ តាំង ប៉ាក់ណាក់ម៉ាមិ ពុទធាំង)

**ប្រែថា** ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើន នូវព្រះអនាបានស្សតិកម្មដ្ឋានលើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**

(យេ ចាក់ ពុទធា អាក់តីតា ចាក់ យេ ចាក់ ពុទធា អាក់ណាគាក់តា)

**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា**

(ប៉ាច់ចុបប៉ាន់ណា ចាក់ យេ ពុទធា អាក់ហាំង វ៉ាន់ទាមិ សាប់ពាក់ទា)

**ប្រែថា** ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ ក្នុងភទ្ទកប្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ**

(អ៊ិតិប៉ិ សោ ភាក់គាក់វ៉ា អាក់រ៉ាក់ហាំង សាំម៉ាសាំពុទធោ)

**វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ**

(វិជ្ជាចាក់រ៉ាក់ណាក់សាំប៉ាន់ណោ សុគាក់តោ លោកាក់វិទូ អាក់ណុតតាក់រ៉ោ)

**បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ**

(ប៉ុរិសាក់ទ័មមាក់សារ៉ាក់ថិ សាត់ថាទេវ៉ាក់មាក់នុសសាណាំង ពុទធោ)

**ភគវាតិ** ភាក់គាក់វ៉ាតិ)

**ប្រែថា ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះ

នាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥ **សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតៈមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាន នូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយគឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**

(ណាត់ថិ មេ សាក់រ៉ាក់ណាំង អាញ់ញុំាង ពុទធោ មេ សាក់រ៉ាក់ណាំង វ៉ាក់រ៉ាំង)

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ៗ**

(អេតេណាក់ សាច់ចាក់វ៉ាច់ជេនាក់ ហោតុ មេ ជាក់យាក់មាំងគាក់លាំង)

**ប្រែ នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណាមិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរលឹក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

*(រួចហើយត្រូវសូមខមាទោសនឹងព្រះសម្មាសម្ពុទ្ធដូច្នេះថា )*

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ**

(អ៊ុតតាក់មាំងគេនាក់ វ៉ាន់ទេហាំង ប៉ាទាក់ប៉ុងសុង វ៉ាក់រុតតាក់មាំង ពុទធេ)

**យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ**

(យោ ខាក់ឡិតោ ទោសោ ពុទធោ ខាក់មាក់តុ តាំង មាក់មាំង)

**ប្រែថា ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

*(ក្រាបថ្វាយ បង្គំម្តង)*

**ធម្មរតនប្បណាម**

**អដ្ឋង្គិកាវិយបថោ ជនានំ មោក្ខប្បវេសាយ**

(អាត់ថាំងគិការីយក្សប៉ាក់ថោ ជាក់នានាំង មោក់ខាប់ប៉ាក់វេសាយាក់)

**ឧជុ ច មគ្គោ ធម្មោ អយំ សន្តិករោ**

(អ៊ុជូ ចាក់ មាគ់គោ ធ័មមោ អាក់យ៉ាំង សាន់តិកាក់រ៉ោ)

**បណីតោ និយ្យានិកោ តំ បនមាមិ ធម្មំ ។**

(ប៉ាក់ណីតោ នីយានិកោ តាំង ប៉ាក់ណាក់ម៉ាមិ ធ័មមាំង)

**ប្រែថា** ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញុំាងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តមជាគុណញុំាងសត្វ ឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសទ្ធម្មនោះ ដោយគោរព ។ *(ក្រាបថ្វាយបង្គំម្តង)*

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**

(យេ ចាក់ ធ័មមា អាក់តីតា ចាក់ យេ ចាក់ ធ័មមា អាក់ណាគាក់តា)

**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា**

(ប៉ាច់ចុបប៉ាន់ណា ចាក់ យេ ធ័មមា អាក់ហាំង វ៉ាន់ទាមិ សាប់ពាក់ទា)

**ប្រែថា** ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះ-ករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

*(ក្រាបថ្វាយបង្គំម្តង)*

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ**

(ស្វាក់ខាតោ ភាក់គាក់វាក់តា ធ័មមោ សាន់ទិដឋិកោ)

**អកាលិកោ ឯហិបស្សិកោ ឱបនយិកោ**

(អាក់កាឡិកោ អេហិប៉ាស់សិកោ អោប៉ាក់ណាក់យិកោ)

**បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

(ប៉ាច់ចាត់តាំង វេទិតាប់ពោ វិញ្ញូហីតិ)

**ប្រែថា ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ (ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១ ) **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់

ដោយខ្លួនឯង **អកាលិកោ** ជាធម៌មិឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គ កើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឱ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

(ក្រាបថ្វាយបង្គំម្តង)

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**

(ណាត់ថិ មេ សាក់រ៉ាក់ណាំង អាញ់ញ៉ាំង ធ័មមោ មេ សាក់រ៉ាក់ណាំង វ៉ាក់រ៉ាំង)

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

(អេតេណាក់ សាច់ចាក់វ៉ាច់ជេនាក់ ហោតុ មេ ជាក់យាក់មាំងគាក់លាំង)

**ប្រែថា: នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះ-

កុរណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

(ក្រាបថ្វាយបង្គំម្ដង)

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ**

(អ៊ុតតាក់មាំងគេនាក់ វាន់ទេហាំង ធ័មមាញ់ចាក់ ទុវិធាំង វាក់រាំង)

**ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ**

(ធ័មមេ យោ ខាក់ឡិតោ ទោសោ ធ័មមោ ខាក់មាក់តុ តាំង មាក់មាំង)

**ប្រែថា ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មាន ២ ប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

*(ក្រាបថ្វាយបង្គំម្ដង)*

## សង្ឃរតនប្បណាម

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ**

(សាំងឃោ វិសុទធោ វ៉ាក់រាក់ទាក់ខិណៃយ៉ោ សាន់តិនទ្រិយោ)

**សព្វមលប្បហីនោ គុណេហិនេកេហិ សមិទ្ធិបត្តោ**

(សាប់ពាក់មាក់ឡាប់ប៉ាក់ហីណោ គុណេហិនេកេហិ សាក់មិទធិប៉ាត់តោ)

**អនាសវោ តំ បនមាមិ សង្ឃំ**

(អាក់ណាសាក់វ៉ោ តាំង ប៉ាក់ណាក់ម៉ាមិ សាំងឃាំង)

**ប្រែថា** ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយ៍រម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួង បន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយ នូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះ-ករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។

**(ក្រាបថ្វាយបង្គំម្តង)**

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**

(យេ ចាក់ សាំងឃា អាក់តីតា ចាក់ យេ ចាក់ សាំងឃា អាក់ណាគាក់តា)

**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា**

(ប៉ាច់ចុបប៉ាន់ណា ចាក់ យេ សាំងឃា អាក់ហាំង វ៉ាន់ទាមិ សាប់ពាក់ទា)

**ប្រែថា** ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ បានសម្រេចមគ្គនិងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ នឹងបាន

សម្រេចមគ្គ និងផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ បានសម្រេចមគ្គ និងផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។

**(ក្រាបថ្វាយបង្គំម្តង)**

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

(សុប៉ាក់ដិប៉ាន់ណោ ភាក់គាក់វ៉ាក់តោ សាវ៉ាក់កាក់សាំងឃោ)

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**

(អ៊ុជុប៉ាក់ដិប៉ាន់ណោ ភាក់គាក់វ៉ាក់តោ សាវ៉ាក់កាក់សាំងឃោ)

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

(ញាយាក់ប៉ាក់ដិប៉ាន់ណោ ភាក់គាក់វ៉ាក់តោ សាវ៉ាក់កាក់សាំងឃោ)

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**

(សាម៊ីចិប៉ាក់ដិប៉ាន់ណោ ភាក់គាក់វ៉ាក់តោ សាវ៉ាក់កាក់សាំងឃោ)

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា**

(យាក់ទិទាំង ចាត់តារិ ប៊ុរិសាក់យុគានិ អាត់ថាក់ប៊ុរិសាក់ប៊ុគគាក់លា)

**ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ**

(អេសាក់ ភាក់គាក់វ៉ាក់តោ សាវ៉ាក់កាក់សាំងឃោ អាហុណៃយ៉ោ)

**បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ**

(ប៉ាហុណៃយ៉ោ ទាក់ខិណៃយោ អាញ់ជាក់លិកាក់រ៉ាក់ណីយ៉ោ)

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

(អាក់ណុតតាក់រ៉ាំង ប៉ុញញ៉ាក់ខេត់តាំង លោកាស់សាតិ)

**ប្រែថា សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់គឺប្រតិបត្តិជាមជ្ឈិមបដិបទា **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីលសមាធិបញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយ មាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និង សោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និង សកទាគាមិផលជាគូ ១ អនាគាមិមគ្គ និង អនាគាមិផលជាគូ ១ អរហត្តមគ្គ និង អរហត្តផលជាគូ ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១

អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ សាវក-សង្ឃោ** ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយ នាំមកពីចម្ងាយបង្អោនចូលមកបូជា **បាហុណេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិនិងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម ហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យ នៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ** (ណាត់ថិ មេ សាក់រ៉ាក់ណាំង អាញ់ញ៉ាំង សាំងឃោ មេ សាក់រាក់ណាំង វ៉ាក់រាំង)

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**
(អេតេណាក់ សាច់ចាក់វ៉ាច់ជេនាក់ ហោតុ មេ ជាក់យាក់មាំងគាក់លាំង)

**ប្រែថា នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹង ទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជា

ម្ចាស់ជាទីពឹង ទីរឭក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះ-ករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ**

(អ៊ុតតាក់មាំងគេនាក់ វ៉ាន់ទេហាំង សាំងឃាញ់ចាក់ ទុវិធោតតាក់មាំុង)

**សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ**

(សាំងឃេ យោ ខាក់ឡិតោ ទោសោ សាំងឃោ ខាក់ម៉ាក់តុ តាំង មាក់មាំង)

**ប្រែថា ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសង្ឃដ៏ប្រសើរ មាន ២ប្រការ គឺ សម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង **សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់ **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

**(ក្រាបថ្វាយបង្គំម្តង)**

## យោគក្បកោដី

**យោ កប្បកោដីហិបិ អប្បមេយ្យំ កាលំ ករោន្តោ**

(យោ កាប់ប៉ាក់កោដីហិបិ អាប់ប៉ាក់មៃ៉យ៉ាំង កាឡាំង កាក់រ៉ោនតោ)

**អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ**

(អាក់តិទុកកាក់រ៉ានិ ខេទាំង គាក់តោ លោកាក់ហិតាយាក់ នាថោ)

**នមោ មហាការុណិកស្ស តស្ស ៥**

(នាក់មោ មាក់ហាការុណិកាស់សាក់ តាស់សាក់)

**ប្រែថា** ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ រាប់ដោយកោដិកប្បា ច្រើនគណនា ហួសគិតគូរ បាន ត្រាស់ជាសព្វញ្ញូ ច្បាស់ជាគ្រូលើភពឋាន ។ ធ្វើកម្មជាកម្រ សត្វនិករត្រាប់ពុំបាន តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៏ដល់សព្វសត្វ ។ ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់ ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ**

(អាក់សាំពុធាំង ពុទធាក់និសេវិតាំង យាំង ភាក់វ៉ាភាក់វាំង គាច់ឆាក់តិ)

**ជីវលោកោ នមោ អវិជ្ជាទិកិលេសជាលំ**

(ជីវ៉ាក់លោកោ នាក់មោ អាក់វិចជាទិកិឡេសាក់ជាលាំង)

**វិទ្ធំសិនោ ធម្មវរស្ស តស្ស**

(វិទធាំងសិណោ ធ័មមាក់វ៉ាក់រះសាក់ តាស់សាក់ )

**ប្រែថា** សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កាមជាគោល ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម គឺព្រះពុទ្ធ សេពសម ចិត្តខ្ញុំសូមនមស្ការ នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា កាត់បង់នូវអវិជ្ជា គឺបណ្តាញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញា វិមុត្តិញ្ញាណបភូតីហិ**

(គុណេហិ យោ សីឡាក់សាក់ម៉ាធិប៉ាញ់ញ៉ា វិមុតតិញញាណាប់ប៉ាក់ភូតីហិ)

**យុត្តោ ខេត្តញ្ញនានំ កុសលត្ថិកានំ**

(យុតតោ ខេតតាញ់ជាក់នានាំង កុសាក់ឡាត់ថិកាណាំង)

**តមរិយសង្ឃំ សិរសា នមាមិ ៕**

(តាក់ម៉ាកិរុយ៉ាក់សាំងឃាំង សិរ៉ាក់សា នាក់មាមិ )

**ប្រែថា** ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់ កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។ និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល។ ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

**ថ្វាយបង្គំសុំសេចក្តីសុខ**

**ឥច្ចេវមច្ចន្ត នមស្សនេយ្យំ**

(អិចចេវ៉ាក់ម៉ាច់ចាន់តាក់ នាក់ម៉ាស់សាក់ណៃយាំង)

**នមស្សមានោ រតនត្តយំ យំ បុញ្ញាភិសន្ទំ**

(នាក់ម៉ាសសាក់ម៉ាណោ រាក់តាក់ណាត់តាក់យ៉ាំង យាំង ប៉ុញញ៉ាភិសាត់ទាំង)

**វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ**

(វិប៉ុឡាំង អាក់ឡាត់ថាំង តាស់សានុភាវេនាក់ ហាក់តាន់តាក់រ៉ាយ៉ោ)

**ប្រែថា** ខ្ញុំសូមនមស្ការ លើហត្ថាឱនសិរសី បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។ សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា ពេញពោរស្មើធារាដូចជលសាធំទូលាយ ។ សូមឱ្យកម្ចាត់បង់ អពមង្គលទាំងឡាយ ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។ ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធានកងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។ ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់ សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

(**ចប់**)

## នមស្ការបូជនីយវត្ថុជាទីគោរព

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ**

(វ៉ាន់ទាមិ ចេតិយ៉ាំង សាប់ពាំង សាប់ព័តថានេសុ ប៉ាក់តិដឋិតាំង)

## សារីរិកធាតុំ មហាពោធឹ ពុទ្ធរូបំ សកលំ សទា ៕

(សារីរិកាក់ធាតុ មាក់ហាពោធឹង ពុទធាក់រូបុំង សាក់កាក់ឡាំង សាក់ទា)

***ប្រែថា*** ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកម្បង់អញ្ជលី ។
នឹងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលឋិតនៅគ្រប់ទី ឋាននានានោះទាំងអស់ ។
ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្ត ។
សូមទាន់ព្រះអរិ- យមេត្រេយ្យថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

## នមស្ការព្រះពុទ្ធបាទ

## វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ

(វ៉ាន់ទាមិ ពុទធាំង ភាក់វ៉ាក់ប៉ា””រ៉ាក់តិនណាំង តិលោកាក់កេតតុង)

**តិភវេកនាថំ យោ លោកសេដ្ឋោ សកលំ**

(តិភាក់វេកាក់នាថាំង យោ លោកាក់សេដថោ សាក់កាក់ឡាំង)

**កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ ១**

(កិឡេសាំង ឆេតត្វានាក់ ពោធេសិ ជាក់នាំង អាក់ណាន់តាំង)

**ប្រែជាពាក្យកាព្យ**

ព្រះសព្វញ្ញុពុទ្ធ វិសេសផុតត្រៃលោកា
គ្មានមនុស្សឬទេវតា ព្រហ្មាណាប្រដូចបាន ។
កម្ចាត់នូវកិលេស គ្មានឱ្យសេសនៅសល់ខាន
ញុំាងជនទាំងប៉ុន្មាន ជាអនន្តឱ្យត្រាស់ដឹង ។
ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង
ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។
ព្រះអង្គជាទង់ជ័យ ធំត្រៃឈៃបង្ហាញត្រើយ
តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។
មារព្រហ្មទាំងទេវ្តា និងមនុស្សាតែងគោរព
ចូលជ្រកនៅក្រោមម្លប់ ពោធិញាណបានសុខា ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ**

(យាំង ណាំមាក់ទាយាក់ នាក់ទិយា ប៉ុឡិនេ ចាក់ តីរ៉េ យាំង)

**សច្ចពន្ធគិរិកេ សុមនា ច លគ្គេ យំ តត្ថ**

( សាច់ចាក់ពាន់ធាក់គីរិកេ  សុមាក់នា  ចាក់  លាត់តេ  យាំង តាត់ថាក់)

**យោនកបុរេ  មុនិនោ  ច  បាទំ  តំ**

(យោនាក់កាក់ប៉ុរេ មុនិនោ  ចាក់  ប៉ាទាំង  តាំង)

**បាទលញ្ឆនមហំ  សិរសា  នមាមិ  ៗ**

(ប៉ាទាក់ឡាញ់ជាក់នាក់មាក់ហាំង  សិរ៉ាក់សា  នាក់មាមិ )

| | | |
|---|---|---|
| សូមថ្វាយបង្គំ | ទសករប្រណម្យ | ឆ្ពោះត្រង់ស្នាមព្រះបាទា |
| ដែលព្រះមានជោគ | ទ្រង់ព្រះមេត្តា | ជាន់ទុកឱ្យជាស្លាកថ្លៃ ។ |
| ព្រះបាទមួយនៅនា | ស្ទឹងនម្មទា | ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ |
| ព្រះបាទមួយទ្រង់ជាន់ | ទុកនៅព្ធ- | ដ៏ភ្នំគិរីសច្ចព័ន្ធ ។ |
| ព្រះបាទមួយនៅភ្នំ | សុមនកូដ | របូតកំពូលដ៏សោភ័ណ |
| ព្រះបាទមួយទៀត | ព្រះទ្រង់ជាន់ | ទុកនៅនាយោនកបុរី ។ |
| ខ្ញុំសូមបន្ទន់ | កាយវាចា | និងចិត្តជ្រះថ្លាឱនសិរសី |
| បង្គំព្រះបាទ | ព្រះជិនស្រី | សូមសុខសួស្តិគ្រប់វេលា ។ |

**សុវណ្ណមាលិកេ  សុវណ្ណបព្វតេ  សុមនកូដេ**

( សុវ៉ាន់ណាក់មាលិកេ  សុវ៉ាន់ណាក់ប៉ាប់ពាក់តេ  សុមាក់នាក់កូដេ)

**យោនកបុរេ  នម្មទាយ  នទិយា**

( យោនាក់កាក់ប៉ុរ៉េ  ណាំមាក់ទាយាក់  នាក់ទិយា)

**បញ្ចាចនចរំ ឋានំ អហំ វន្ទាមិ ទូរតោ ២**

( ប៉ាញ់ចាក់ប៉ាទាក់វាក់រាំង ឋាណាំង អាក់ហាំង វាន់ទាមិ ទូរាក់តោ)

**ប្រែថា** ខ្ញុំសូមនមស្ការ អំពីចម្ងាយ នូវឋានទាំងឡាយ ដែលមានព្រះបាទ ទាំងប្រាំកន្លែង ដែលព្រះមុនីនាថ ទ្រង់យាងព្រះបាទ លើកំពូលភ្នំ ។ សុវណ្ណមាលិក មួយនោះជាធំ មួយនៅលើភ្នំ សុវណ្ណបពិត មួយនៅលើភ្នំ សុមនកូដប្រាកដ មួយនៅរាជរដ្ឋ យោនកបុរី ។ មួយនៅនៅក្បែរស្ទឹង នម្មទាជលធី ទាំងប្រាំនាទី ដែលទ្រង់ប្រទាន ទុកឱ្យសព្វសត្វ ប្រតិបត្តិជាស្ពាន ដែលព្រះទ្រង់ញាណ ប្រទានទុកឱ្យ ។

# វិធីសមាទានសីល ៥ (និច្ចសីល)

**ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

(អ៊ុកាសាក់ មាក់យាំង ភាន់តេ វិសុង វិសុង រាក់ខាក់ណាត់ថាយាក់)

**តិសរណេន សហ បញ្ចសីលានិ យាចាម ។**

(តិសាក់រាក់ណេនាក់ សាក់ហាក់ ប៉ាញ់ចាក់សីឡានិ យាចាមាក់)

**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

(ទុតិយ៉ាំប៉ិ មាក់យាំង ភាន់តេ វិសុង វិសុង រាក់ខាក់ណាត់ថាយាក់)

**តិសរណេន សហ បញ្ចសីលានិ យាចាម ។**

(តិសាក់រាក់ណេនាក់ សាក់ហាក់ ប៉ាញ់ចាក់សីឡានិ យាចាមាក់)

**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

(តាក់តិយ៉ាំប៉ិ មាក់យាំង ភាន់តេ វិសុង វិសុង រាក់ខាក់ណាត់ថាយាក់)

**តិសរណេន សហ បញ្ចសីលានិ យាចាម ។**

(តិសាក់រាក់ណេនាក់ សាក់ហាក់ ប៉ាញ់ចាក់សីឡានិ យាចាមាក់)

**អនុគ្គហំ កត្វា សីលំ ទេថ { មេ / នោ } ភន្តេ ។**

(អនុគគាក់ហាំង កាត់ត្វា សីឡាំង ទេថាក់) ភាន់តេ ។

(ទើបព្រះសង្ឃសូធ្យថា)

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៥**

(នាក់មោ ពាស់សាក់ ភាក់គាក់វាក់តោ អាក់រ៉ាក់ហាក់តោ សាំម៉ាសាំពុទ ធាស់សាក់) ។ ***(សូធ្យបីដង)***

**ពុទ្ធំ សរណំ គច្ឆាមិ** (ពុទធាំង សាក់រ៉ាក់ណាំ គាច់ឆាមិ)

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក

**ធម្មំ សរណំ គច្ឆាមិ** (ធ័មមាំង......)

ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក

**សង្ឃំ សរណំ គច្ឆាមិ** (សាំងឃាំង......)

ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** (ទុតិយ៉ាំ ប៉ិ......)

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក ជាគម្រប់ពីរដងផង

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** (ទុតិយ៉ាំ ប៉ិ......)

ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក ជាគម្រប់ពីរដងផង

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** (ទុតិយ៉ាំ ប៉ិ......)

ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក ជាគម្រប់ពីរដងផង

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** (តតិយ៉ាំ ប៉ិ......)

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក ជាគម្រប់បីដងផង

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** (តតិយ៉ាំ ប៉ិ......)

ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក ជាគម្រប់បីដងផង

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** (តតិយ៉ាំ ប៉ិ......)

ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក ជាគម្រប់បីដងផង

**(ចប់ការដល់ព្រះត្រៃសរណគមន៍)**

ព្រះសង្ឃសូធ្យថា: **តិសរណគមនំ បរិបុណ្ណំ** (តិសាក់រ៉ាក់ណាក់គាក់ហាក់ណាំង ប៉ាក់រិប៊ុនណាំង) **ប្រែថា** ការកាន់នូវត្រៃសរណគមន៍ ពេញបរិបូណ៌ ។

ឧបាសក-ឧបាសិកា ត្រូវពោលថា **អាម ភន្តេ** ករុណា លោកម្ចាស់ ។

**១. បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**

(ប៉ាណាតិប៉ាតា វេរាក់មាក់នី សិកខាប៉ាក់ទាំង សាក់ម៉ា ទិយាមិ)

**ប្រែថា** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**២. អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**

(អាក់ទិននាទានា វេរាក់មាក់នី សិកខាប៉ាក់ទាំង សាក់ម៉ាទិយាមិ)

**ប្រែថា** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ។

**៣. កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ**

( កាម៉េសុ មិចឆាចារ៉ា វេរាក់មាក់នី សិកខាប៉ាក់ទាំង សាក់ម៉ាទិយាមិ)

**ប្រែថា** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**៤. មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ**

( មុសាវ៉ាទា វេរាក់មាក់នី សិកខាប៉ាក់ទាំង សាក់ម៉ាទិយាមិ)

**ប្រែថា** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។

**៥.សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមា~ ទិយាមិ** ( សុរ៉ាមេរាក់យាក់មាច់ជ័បប៉ាក់ម៉ាទ័តឋាណា វេរាក់មាក់នី ......)

**ប្រែថា** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

**ព្រះសង្ឃសូធ្យរំលឹកថា**

**ឥមានិ បញ្ចសិក្ខាបទានិ សាធុកំ កត្វា**

( អ៊ិម៉ានិ ប៉ាញ់ចាក់សិកខាប៉ាក់ទានិ សាធុកាំង កាត់ត្វា)

**អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។**

( អាប់ប៉ាក់ម៉ាទេនាក់ និចចាក់កាឡាំង សាំម៉ារាក់ខិតាប់ពាំង)

**ប្រែថា** អ្នក (អ្នកទាំងឡាយ) គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

ឧបាសក- ឧបាសិកាពោលថា **អាម ភន្តេ** ករុណា លោកម្ចាស់ ។

**ព្រះសង្ឃសូធ្យប្រកាសអានិសង្សសីល**

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

(សីឡេនាក់ សុគាក់តឹង យ័នតិ សីឡេនាក់ ភោគាក់សាំប៉ាក់ទា)

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ**

(សីឡេនាក់ និពពុតឹង យ័នតិ តាស់ស្មា សីឡាំង វិសោធាក់យេ)

**ប្រែថា** សត្វទាំងឡាយ បានទៅកាន់ឋានសួគ៌ក៏ព្រោះសីល សត្វទាំង-ឡាយ បានបរិបូណ៌ដោយភោគៈក៏ព្រោះសីល សត្វទាំងឡាយ បានទៅកាន់ទីរំលត់ទុក្ខ ពោលគឺព្រះនិព្វានក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។

**(ចប់វិធីសមាទានសីល ៥ តែប៉ុណ្ណោះ)**

# វិធីសមាទានឧបោសថសីល

បើឧបាសកឧបាសិកា សមាទាននូវឧបោសថសីលប្រកបដោយអង្គ ៨ ជាបច្ចេកសមាទានពីភិក្ខុ ឬសាមណេរ នោះត្រូវសូចធ្យនមស្ការ ហើយសូមនូវឧបោសថសីល ព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះនឹងភិក្ខុ ឬសាមណេរ ។

**ឱកាស (អហំ/មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ (យាចាមិ/យាចាម) អនុគ្គហំ កត្វា សីលំ ទេថ (មេ/នោ) ភន្តេ,**

**ទុតិយម្បិ (អហំ/មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ (យាចាមិ/យាចាម) អនុគ្គហំ កត្វា សីលំ ទេថ (មេ/នោ) ភន្តេ,**

**តតិយម្បិ (អហំ/មយំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ (យាចាមិ/យាចាម) អនុគ្គហំ កត្វា សីលំ ទេថ (មេ/នោ) ភន្តេ ។**

*ឧបោសថសីល*

**១. បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា ធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**២. អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា កាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយឬដោយវាចា ។

**៣. អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា ប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

**៤. មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា ពោលនូវពាក្យកុហក ។

**៥.សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

**៦. វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក

កិរិយាបរិភោគនូវភោជនាហារ ក្នុងកាលខុស ។

**៧.នច្ចគីតវាទិតវិសូកទស្សន មាលាគន្ធវិលេបនធារណ-មណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែង ដែលជាសត្រូវ ដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**៨.ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិ-យាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណនិងទីសេនាសនៈដ៏ប្រសើរ ។

***រួចហើយអ្នកសមាទានសូមឲ្យកំណត់ឧបោសថកាលថា***

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីលដ៏ប្រកបព្រមដោយអង្គ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តិទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ ប្រពៃអស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូលជាឧបនិស្ស័យ ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានពួដ៏អនាគតទៅឯមុខនោះ ហោង។

*ព្រះសង្ឃវំពុកថា*

**ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ** (អ្នក/អ្នកទាំងឡាយ) គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អ ដោយអំណាចឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

***អានិសង្សសីល***

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

សត្វទាំងឡាយបានទៅកាន់ឋានសួគ៌ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វានក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះ នូវសីលឱ្យ បរិសុទ្ធកុំឱ្យសៅហ្មងឡើយ ។

***អ្នកសមាទានត្រូវទទួលថា* សាធុ** ប្រពៃហើយ

វិធីសមាទានឧបោសថសីល ជាបច្ចេកសមាទានចប់តែប៉ុណ្ណោះ ។

# បត្តិទានគាថា [សូត្រចែកបុណ្យ]

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម**

(យាំង កិញ្ចិ កុសាក់ឡាក់កាំមុាំង កាត់តាប់ពាំង កិរិយុាំង មាក់មាក់)

**កាយេន វាចា មនសា តិទសេ សុគតំ កតំ យេ**

(កាយេនាក់ វាចា មាក់នាក់សា តិទាក់សេ សុគាក់តាំង កាក់តាំង យេ)

**សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ**

(សាត់តា សាញ់ញុិណោ អាត់ថិ យេ ចាក់ សាត់តា អាក់សាញ់ញុិណោ)

**កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ**

(កាក់តាំង ប៉ុញ្ញ៉ាក់ផាក់ឡាំង ម៉ៃហាំង សាប់ពេ ភាគី ភាក់វាន់តុ តេ)

**យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា**

(យេ តាំង កាក់តាំង សុវិទិតាំង ទិននាំង ប៉ុញ្ញ៉ាក់ផាក់ឡាំង មាក់យា)

**យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ សព្វេ**

(យេ ចាក់ តាត់ថាក់ នាក់ ជាណន់តិ ទេវា គាន់ត្វា និវេទាក់យុង សាប់ពេ)

**លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ**

(លោកាំម្ហិ យេ សាត់តា ជីវាន់តាហារាក់ហេតុកា មាក់នុញ្ញាំង)

**ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។**

(ភោជាក់នាំង សាប់ពេ លាក់ភាន់តុ មាក់មាក់ ចេតាក់សាតិ)

**ប្រែថា យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ **កាយេន វាចាមនសា** ដោយទ្វារទាំង ៣ គឺ កាយ វាចា ចិត្ត **តិទសេ សុគតំ កតំ** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំ ឱ្យកើតក្នុងឋានត្រៃត្រឹង្សសួគ៌បាន **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំង-ឡាយឯណាជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយទាំងអស់នោះចូរឱ្យបាននូវចំណែកផលនៃបុណ្យដែលខ្ញុំបានធ្វើហើយបានឧទ្ទិសផ្សាយឱ្យទៅនេះចុះ **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឱ្យនេះទៅចុះ **យេ ច តត្ថ ន ជានន្តិ**ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំង-ឡាយ អញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះ ឱ្យបានដឹងផងថា ជនឯ-ណោះ គេបានធ្វើបុណ្យហើយឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំង-ឡាយៗ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេទាំងនោះចុះ **សព្វេ លោកម្ហិ**

**យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណា ក្នុងលោកទាំងអស់ដែលអាស្រ័យនូវអាហារហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ** សត្វទាំងឡាយទាំងអស់នោះ ចូរបាននូវភោជនជាទីគាប់ចិត្តដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តនៃខ្ញុំដែលឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។

## ឧទ្ទិសកុសលជាពាក្យកាព្យ

| | |
|---|---|
| កម្មជាកុសលឯណា | ដែលជាការឥតសៅហ្មង |
| យើងខ្ញុំបានកសាង | ដោយទ្វារកាយ វាចា ចិត្ត |
| កុសលទាំងអស់នោះ | អាចជួយដោះជួយបង្ខិត |
| នាំសត្វឱ្យជាប់ចិត្ត | ស្ថិតនៅនាស្ថានឧត្តម ។ |
| សត្វណាមានសញ្ញា | មនុស្ស ទេវតា ឬឥន្ទព្រហ្ម |
| ដែលមានស័ក្តិតូចធំ | ព្រមទាំងសត្វឥតសញ្ញា ។ |
| សូមបានចំណែកបុណ្យ | ដែលជាគុណល្អថ្លៃថ្លា |
| យើងខ្ញុំបានរចនា | ចាត់ចែងការកុសលហ្នឹង ។ |
| ម្យ៉ាងទៀតសត្វឯណា | ឆ្ងាយអស្ចារ្យពុំបានដឹង |
| សូមទេវតាទៅប្តឹង | ឱ្យដំណឹងយ៉ាងនេះថា ។ |

នរជននៅឯនុ៎ះ ស្រីឬប្រុសបានជ្រះថ្លា
កសាងបុញ្ញកិរិយា វត្ថុជាផ្លូវឆើតឆាយ ។
ហើយគេឧទ្ទិសផល ឱ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តស្រស់ស្រាយ បន្ទន់កាយទទួលយក ។
សត្វលោកទាំងអស់នោះ ដែលបានរស់តរៀងមក
ដោយបានបរិភោគ នូវអាហារទើបរស់បាន ។
សត្វទាំងអស់នោះណា បានសុខាសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន សូមឱ្យបានកុំខានឡើយ ។

## ធម៌ឧទ្ទិសផល

ទានសីលដែលខ្ញុំបានធ្វើហើយ ព្រះគុណអើយខ្ញុំសច្ចា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ ។
ជីដូន និង ជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល ។
ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានឱ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា ។
កុសលទាំងអស់ហ្នឹង សូមទីពឹងលើទេវតា

ដែលមានចិត្តមេត្តា　　នាំផលាទាំងអស់នេះ ។
ទៅជូនឱ្យខ្ញុំផង　　ដូចបំណងកុំបីធ្វេស
កូនចៅនៅឯណេះ　　មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ　　ដោយសប្បាយទទួលយក
កូនចៅបានលៃលក　　បញ្ជូនមកគ្រប់ៗគ្នា ។
ដើម្បីសោយកំសាន្ត　　សូមឱ្យបាននៅសុខជា
កូនចៅទាំងអស់គ្នា　　បានបូជាជូនទៅហោង ។

## ធម៌ឧទ្ទិសសង្ខេប

ទានសីលយើងទាំងឡាយ　　សូមផ្សព្វផ្សាយដល់ញាតិមិត្ត
ទៅកាន់ទីឆ្ងាយជិត　　មានវិបត្តិយ៉ាងណាក្តី
សូមឱ្យរួចរំដោះ　　ចាកទុក្ខទោសគ្រោះចង្រៃ
បានសុខរៀងរាល់ថ្ងៃ　　ដរាបដល់និព្វានហោង ។

# បាលីវេរសង្ឃទាន

មយំ ភន្តេ ឥមានិ ខាទនីយ ភោជនីយានិ សជ្ជេត្វា

( មាក់យាំង ភាន់តេ អ៊ិម៉ានិ ខាទាក់នីយក្យ ភោជាក់នីយាទីនិ សាច់ជេត្វា)

សង្ឃស្ស ទេម សាធុ នោ ភន្តេ សង្ឃោ ឥមានិ

( សាំងឃាស់សាក់ ទេមាក់ សាធុ នោ ភាន់តេ សាំងឃោ អ៊ិម៉ានិ)

ខាទនីយភោជនីយានិ បដិគ្គណ្ហតុ មាតាបិតុ

( ខាទាក់នីយក្យភោជាក់នីយានីនិ ប៉ាក់ដិគគន់ហាក់តុ មាតាបិុតុ)

អាទីនំ គុណវន្តានញ្ច អម្ហាកញ្ច

( អាទីណាំង គុណាក់វ៉ាន់តាណាញ៉ូចាក់ អាំម្ហាកាញ៉ូចាក់)

ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

(ទុតិយម្បិ...តតិយម្បិ...)

( ទីឃាក់រាត់តាំង អាត់ថាយាក់ ហិតាយាក់ សុខាយាក់) ( ទុតិយាំបិ តាក់តិយាំបិ )

**ប្រែថា** បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន យើងខ្ញុំព្រះករុណាទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែម និង

ចម្អាបជាដើមនេះ មកវេរប្រគេនចំពោះព្រះសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវវត្ថុទាំងឡាយ មានបង្អែម និងចម្អាបជាដើមនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៏ ដើម្បីសេក្ដីសុខដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

## ផ្សាយមេត្តាចំពោះសព្វសត្វទាំង ១០ ទិស

**សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុងទិសបូព៌ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុងទិសអាគ្នេយ៏ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុងទិសទក្សិណ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុងទិសនិរតី សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុងទិសបស្ចិម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុទិសពាយ័ព្យ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុងទិសឧត្តរ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុងទិសឦសាន សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុងទិសខាងក្រោម សូមកុំឱ្យមាន

ពៀរនឹងគ្នា  មានតែសេចក្ដីសុខ ។

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**

សត្វទាំងឡាយទាំងពួង "ដែលស្ថិតនៅ" ក្នុងទិសខាងលើ សូមកុំឱ្យមានពៀរនឹងគ្នា  មានតែសេចក្ដីសុខ ។

**សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា**

(សាប់ពេ  សាត់តា  អាក់វេរា ហោនតុ សុខិតា ហោនតុ  និទទុកខា)

**ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា**

(ហោនតុ  អាប់ព្យាប៉ាច់ឈា ហោនតុ  អាក់នីឃា  ហោនតុ  ទីឃាយុកា)

**ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី**

(ហោនតុ  អាក់រោគា  ហោនតុ សាំប៉ាត់តីហិ  សាក់មិជឈាន់តុ  សុខី)

**អត្តានំ  បរិហរន្តុ ៕** (អាត់តាណាំង ប៉ាក់រិហាក់រ៉ន់តុ)

សូមឱ្យសត្វទាំងឡាយទាំងពួង កុំមានពៀរនឹងគ្នា សូមឱ្យបាននូវសេចក្ដីសុខ ឱ្យប្រាសចាកទុក្ខ  កុំព្យាបាទគ្នា  កុំមានសេចក្ដីព្រួយចំបែង  សូមឱ្យមានអាយុវែង កុំឱ្យមានរោគ  សូមឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយ   សូមរក្សានូវខ្លួនឱ្យជាសុខតរៀងទៅ ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**

(ទុកខាប់ប៉ាត់តា  ចាក់ និតទុកខា ភាក់យ៉ាប់ប៉ាត់តា ចាក់ និបភាក់យា)

**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។**

( សោកាប់ប៉ាត់តា ចាក់ និសសោកា ហោនតុ សាប់ពេបិុ ប៉ាណិនោ ។

សត្វទាំងឡាយទាំងពួង ដែលកំពុងដល់នូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលកំពុងដល់នូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលកំពុងដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅហោង ។

## សុភមង្គលគាថា

**ហោតុ សព្វំ សុមង្គលំ   រក្ខន្តុ   សព្វទេវតា**

(ហោតុ សាប់ពាំង សុមាំងគាក់លាំង រាក់ខាន់តុ សាប់ពាក់ទេវតា)

**សព្វពុទ្ធានុភាវេន   សព្វធម្មានុភាវេន**

(សាប់ពាក់ពុធធានុភាវេនាក់   សាប់ពាក់ធ័មមានុភាវេនាក់)

**សព្វសង្ឃានុភាវេន   សោត្ថិ ហោតុ និរន្តរំ ។**

(សាប់ពាក់សាំងឃានុភាវេន សោតថិ ហោតុ និរ៉ន់តាក់រ៉ាំង)

**ប្រែថា ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្តីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ **សព្វពុទ្ធានុភាវេន** ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ **សព្វធម្មានុភាវេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង **សព្វសង្ឃា-**

**នុភាវេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តី ចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

## បរិត្តភាសនាយាចនគាថា

សូមឱ្យព្រះពុទ្ធសាសនា រុងរឿងចម្រើន សូមឱ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឱ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ។

ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្ដីសុខដទៃ ក្រៅអំពីសេចក្ដីស្ងប់ឡើយ ។

## ធម៌សូធ្យសុំសេចក្ដីសុខ

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

(អាកាសាត់ថា ចាក់ ភុមម៉ាត់ឋា ទេវ៉ា នាគា មាក់ហិទធិកា)

**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។**

(ប៉ុញញ៉ាំង នោ អាក់នុមោទាន់តុ ចិរ៉ាំង រាក់ខាន់តុ សាសាក់ណាំង)

**ប្រែថា** ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្ដី ដែលឋិតលើផែនដីក្ដី នាគទាំងឡាយ ដែលមានឫទ្ធិច្រើនក្ដី សូមអនុមោទនានូវបុណ្យរបស់យើង

ទាំងឡាយ សូមរក្សានូវព្រះពុទ្ធសាសនា (ឱ្យឋិតថេរ និងឱ្យរុងរឿង) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។**

**ប្រែថា** ទេវតាទាំងឡាយ ដែលឋិតឮដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយ ដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះរាជាទាំងឡាយ (ឱ្យបានសុខចម្រើន) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។**

**ប្រែថា** ទេវតាទាំងឡាយ ដែលឋិតឮដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយ ដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវសាច់ញាតិទាំងឡាយ (ឱ្យចម្រុងចម្រើន និងសុខសាន្ត) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។**

**ប្រែថា** ទេវតាទាំងឡាយ ដែលឋិតព្ធដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយ ដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវសត្វទាំងឡាយ (ឱ្យចម្រុងចម្រើននិង សុខសាន្ត) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ**[១] **អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ។**

**ប្រែថា** ទេវតាទាំងឡាយ ដែលឋិតព្ធដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយ ដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវយើងទាំងឡាយ (ឱ្យបានចម្រុងចម្រើន និង សុខសាន្ត) អស់កាល ជាយូរគ្រប់កាលទាំងពួង ។

ដកស្រង់ពីគិហិបតិបត្តិ សម្តេច **ជួន ណាត, ហួត តាត**

(១) បុញ្ញំ នោ បើសូត្រម្នាក់ឯងត្រូវថា បុញ្ញំ មេ ប្រែថា: បុណ្យរបស់ខ្ញុំ។

## បត្ថិនានគាថា

**យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ**

(យា ទេវ៉ាក់តា សាន់តិ វិហារាក់វ៉ាសិណី ថូប៉េ ឃាក់រេ)

**ពោធិឃរេ តហឹ តហឹ តា ធម្មទានេន ភវន្តុ**

(ពោធិឃាក់រេ តាក់ហឹងៗ តា ធ័មមាក់ទានេទាក់ ភាក់វ៉ាន់តុ)

**បូជិតា សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ថេរា**

(ប៉ូជិតា សោតថឹង កាក់រ៉ោន់តេធាក់ វិហារាក់ម៉ាន់ឌាក់លេ ថេរ៉ា)

**ច មជ្ឈា នវកា ច ភិក្ខវោ សារាមិកា ទានបតី**

(ចាក់ ម៉ាច់ឈា នាក់វ៉ាក់កា ចាក់ ភិកខាក់វ៉ោ សារ៉ាមិកា ទានាក់ប៉ាក់តី)

**ឧបាសកា គាមា ច ទេសា និគ្គមា ច ឥស្សរា**

(អ៊ុកប៉ាសាក់កា គាមា ចាក់ ទេសា និគគាក់មា ចាក់ អ៊ិសសាក់រ៉ា)

**សប្បាណភូតា សុខិតា ភវន្តុ តេ ជលាពុជា យេបិ**

(សាប់ប៉ាណាក់ភូតា សុខិតា ភាក់វ៉ាន់តុ តេ ជាក់លាពុជា យេប៉ិ)

**ច អណ្ឌសម្ភវា សំសេទជាតា អថ វោ បបាតិកា**

(ចាក់ អាន់ឌាក់សាំភាក់វ៉ា សាំងសេទាក់ជាតា អាក់ថាក់ វ៉ោ ប៉ាក់ប៉ាតិកា)

**និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ**

(និយានិកាំង ធ័មមាក់វ៉ាក់រាំង ប៉ាក់ដិចចាក់តេ សាប់ពេប៉ិ)

**ទុក្ខស្ស ករោន្តុ សំខយំ ឋាតុ ចិរំ សតំ**

(ទុកខាស់សាក់ កាក់រ៉ោនតុ សាំងខាក់យ៉ាំង ឋាតុ ចិរ៉ាំង សាក់តាំង)

**ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ ហោតុ**

(ធ័មមោ ធ័មមាក់ធាក់រា ចាក់ ប៉ុគគាក់លា សាំងឃោ ហោតុ)

**សមគ្គោវ អត្ថាយ ច ហិតាយ ច អម្ហេ**

(សាក់មាក់គោវ៉ាក់ អាត់ថាយាក់ ចាក់ ហិតាយាក់ ចាក់ អាំម្ហេ)

**រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍឹ**

(រ៉ាក់ខាក់តុ សាត់ធ័មមោ សាប់ពេបិ ធ័មមាក់ចារិណោ វុឌ្ឍឹង)

**សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ ។**

(សាំប៉ាប៉ុណើយ៉ាមាក់ ធ័មមារិយ៉ាប់ប៉ាក់វេទិតេ)

ប្រែថា **យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងវត្ត ជាទីនៃសង្ឃព្ធដ៏ខឿនព្រះសថូប ព្ធដ៏ខឿនព្រះពោធិព្រឹក្សក្នុងទីនោះៗ **តា ធម្មទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះ ជាបុគ្គលគឺយើងទាំងឡាយបូជាហើយដោយធម្មទាន **សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយ ជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី

**សារាមិកា ទានបតី ឧបាសកា** ឧបាសក និង ឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជន គឺញ្ញោមវត្តក្តី **គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី **សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះៗ ចូរឱ្យបានដល់នូវសេចក្តីសុខ **ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថ ទោ បបាតិកា** មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជះកំណើតក្តី ដែលជាអណ្ឌជះកំណើតក្តី ដែលជាសំសេទជះកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី **និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ **ឋាតុ ចិរំ សតំ ធម្មោ** សូមឱ្យធម៌ របស់សប្បុរសទាំងឡាយ ឋិតនៅអស់កាលយូរអង្វែងទៅ **ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរឋិតនៅអស់កាលយូរអង្វែងទៅ) **សង្ឃោ ហោតុ សមគ្គោវ** សូមព្រះសង្ឃព្រមព្រៀងគ្នា **អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្តីចម្រើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង **អម្ហេ រក្ខតុ**

**សព្វេ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សាអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយ ទាំងអស់ផង **វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ** សូមឱ្យយើងទាំងឡាយបានដល់នូវសេចក្ដីចម្រើន ក្នុងធម៌ដែលព្រះអរិយៈទាំងឡាយ លោកសម្ដែងហើយ ។

## ធម៌ឧទ្ទិសទាន

| | | |
|---|---|---|
| រីកុសលទានសីល | ខ្ញុំសូមផ្ដាច់ផ្ដិល | មន្ទិលទោសា |
| ថ្វាយទានថ្មីៗ | ដោយក្ដីជ្រះថ្លា | ដោយកាយវាចា |
| | ចិត្តឥតហ្មងសៅ ។ | |
| កុសលទាំងនោះ | ខ្ញុំសូមឧទ្ទិស | ដល់ម្ចាស់ដើមទាន |
| មាតាបិតា | គ្រូអាចារ្យញាតិផៅ | ទោះស្លាប់ឬនៅ |
| | បានដូចបំណង ។ | |
| កុសលទាំងនេះ | ទុកជាជំនិះ | ជិះកាត់ចម្លង |
| ឱ្យរួចផុតទុក្ខ | ទាំងដប់ពីរកង | សោយសុខកន្លង |
| | ដល់ឋាននិព្វាន ។ | |

## ធម៌សម្រាប់សូត្រឧទ្ទិសផល

សូមឱ្យអ្នកទាំងឡាយ សុខសប្បាយទាំងអស់គ្នា

កុំឱ្យមានរោគា ព្រមទាំងញាតិមិត្តសន្តាន ។
ចូរខំប្រឹងប្រព្រឹត្ត សាងសុចរិតធម៌ឱ្យបាន
សព្វថ្ងៃសាសនាមាន ខំធ្វើទាន សីល ភាវនា ។
កើតមកក្នុងលោកីយ៍ ទាំងប្រុសស្រី មានវាសនា
ខំប្រឹងរៀនធម៌អាថ៌ ទាន់សាសនាព្រះទ្រង់ញាណ ។
ត្បិតយើងមិនដឹងផ្លូវ នឹងដើរទៅកាន់និព្វាន
ជាទីសុខក្សេមក្សាន្ត លះបង់បានចាកមន្ទិល ។
ជាធម៌ប្រពៃពិត វិសេសសិដ្ឋនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្តាញកិលេសហោង ។

## តេជះខ្ញុំសាង

តេជះខ្ញុំសាង សម្អិតសម្អាង ឱនកាយវាចា
សូមសុខសោភា រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។
គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីល និងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ឋានថ្លៃថ្លា ។
សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា

ព្រមទាំងគុណគ្រូ ឧបជ្ឈាយាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន ។
ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកឋាន
សូមជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ឋានផុតទុក្ខ ។
ខ្ញុំសូមសច្ចា កើតជាតិណា១ សូមឱ្យបានសុខ
សូមមានបញ្ញា ភ្លឺថ្លាមុះមុត រួចផុតពីទុក្ខ
ដល់និព្វានហោង ។

# គោតមប្រវត្តិ

ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្តាដ៏មានបុណ្យ
នឹងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន ។
មកចាប់ផ្ទៃមាតា ស្រីស្រីង្គារស្រស់កល្យាណ
កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។
ក្នុងថ្ងៃព្រហស្បតិ៍អា- សាធមាសាពេញបូណ៌មី
រកាជាឆ្នាំថ្មី សុខសិរីដល់ជនា ។
កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន ។

កក្រើកផែនពសុធា មានទេវតារាប់រយពាន់
ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី ។
ឆ្នាំចពិសាខនា ថ្ងៃសុក្រជាពេញបូណ៌មី
ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ ។
កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកស្នួយ អភិសេកនឹងស្រីង្គារ ។
នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។
កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី
អាសាធពេញបូណ៌មី ក្សត្រាថ្លៃបានសុខា ។
ស្ដេចមានព្រះរាជបុត្រ បរិសុទ្ធភ័ក្ត្រស្រស់ថ្លា
គួរឲ្យព្រះរាជា ស្ដេចជំពាក់ចិត្តពេកក្រៃ ។
តែទ្រង់បានកាត់ផ្ដាច់ ទ្រង់សម្រេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា ។
បើបិតាបានត្រាស់ វិលរហ័សរកបុត្រា
មកប្រោសស្នួនពុំងា ចាកសង្សារណាបុត្រថ្លៃ ។
កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី
អាសាធពេញបូណ៌មី ក្សត្រាថ្លៃចេញបព្វជ្ជា ។
កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
ធ្វើទុក្ករកិរិយា គ្មាននរណាធ្វើដូចអី ។
បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី

ជាថ្ងៃព្រះជិនស្រី មានសិរីឈ្មោះក្រុងមារ ។
ត្រាស់ដឹងបានពីរខែ ទ្រង់គ្មាន់គ្មេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា នាកណ្ដាលដងព្រឹក្សព្រៃ ។
គឺក្នុងឆ្នាំរកា អាសាធមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្ដើមពោលស្ដីធម៌ទេសនា ។
ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្ដា មានរហូតដល់សព្វថ្ងៃ ។
នាថ្ងៃមួយនោះណា គួរសោកាណាស់ម្ចាស់ថ្លៃ
គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ ។
គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
នៅចំពោះមុខមារ នាបាវាលចេតិយ ។
បីខែកន្លងទៅ មិនឈប់នៅយឺនយូរអី
ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា ។
គឺក្នុងឆ្នាំនោះឯង មានការផ្សេងតែមាសា
គឺខែពិសាខនា ថ្ងៃអង្គារពេញបូណ៌មី ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍
នឹកគុណព្រះមុនី សូត្រប្រវត្តិព្រះសាស្ដា ។
សូមឲ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិអារ្យ ជាសាស្ដាដ៏ពិសិដ្ឋ
សូមចាក់ផ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

## ធម៌សូធ្យឧទ្ទិសបុណ្យ

សូមមហាកុសល ដែលបានតម្កល់
ទុកក្នុងចិត្តហើយ សូមជួយរុញច្រាន
ឆាប់បានដល់ត្រើយ កុំបីខានឡើយ
ដូចក្តីប្រាថ្នា ។
សូមឧទ្ទិសផល គោរពជូនដល់
មាតាបិតា ដល់ញាតិសន្តាន
ក្នុងវដ្តសង្សារ ទាំងគ្រូអាចារ្យ
ឧបជ្ឈាយ៍ទាំងឡាយ ។
ទោះរស់ជុំញាតិ ឬស្លាប់បែកឃ្លាត
ចាប់ជាតិជិតឆ្ងាយ សូមបានអាហារ
បរិក្ខារទាំងឡាយ រីករាយសប្បាយ
នឹងបុណ្យកុសល ។
ដែលយើងខ្ញុំបាន ធ្វើទាំងប៉ុន្មាន
ឧទ្ទិសជូនដល់ សូមឲ្យបានសុខ
ផុតទុក្ខកង្វល់ លុះបានមគ្គផល
ដល់ព្រះនិព្វាន ។

## ពាក្យសូមប្រាថ្នា

ខ្ញុំសូមសច្ចា ប្តឹងអស់ទេវតា សោឡសសួគ៌ឋាន
លោកកត់សម្គាល់ ដោយទិព្វវិញ្ញាណ ខ្ញុំប្រតិស្ឋាន
ចំពោះព្រះអង្គ ។

ខ្ញុំធ្វើបុណ្យទាន ធ្វើសីលប៉ុន្មាន ចិត្តខ្ញុំស្មោះត្រង់
ចំពោះព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ ទេវតាគ្រប់អង្គ
ជួយជាសាក្សី ។

ជាតិនេះទៅមុខ កុំឲ្យមានទុក្ខ សូមសុខសួស្តី
បច្ចុប្បន្នទាន់ព្រះ សិអារ្យមេត្រីយ៍ ផុតពីលោកីយ៍
ដល់បរលោកនាយ ។

កុសលតូចធំ ខ្ញុំសាងសន្សំ មគ្គផលទាំងឡាយ
សូមនាំវិញ្ញាណ ទៅបរលោកនាយ ចៀសចាកអបាយ
កំណើតទាំង ៤ ។

កុំឲ្យឃើញយល់ កម្មអកុសល កុំជិតដល់ខ្លួន
សូមឲ្យរួចផុត រលត់សាបសូន្យ មគ្គផលជួយជូន
ឲ្យបានសម្រេច ។

ដូចក្តីប្រាថ្នា ចិត្តខ្ញុំជ្រះថ្លា ចងចាំមិនភ្លេច
កសាងសីលទាន ទោះច្រើនឬតិច ឲ្យបានសម្រេច
ដល់និព្វានហោង ។

## ពុទ្ធកិច្ច ៥ យ៉ាង

គ្រាកាលព្រះសម្ពុទ្ធ ប្រសើរផុតដ៏ឧត្តម

បានត្រាស់ជាបឋម                    សែសិបប្រាំព្រះវស្សា ។
បំពេញពុទ្ធកិច្ច                      មិនដែលដាច់វេលាណា
សម្មតិឈ្មោះហៅថា                  ពុទ្ធក្រិត្យាមានប្រាំយ៉ាង ។
**ទី១** គឺពេលព្រឹក                   ដ៏ពន្លឺកពន្លឺស្វាង
ព្រះអង្គស្ដេចទ្រង់យាង             ចេញបិណ្ឌបាតប្រោសសព្វសត្វ ។
**ទី២** រសៀលជ្រេ                  ព្រះសុរិយេពេលទៀបស្វាត់
ទេសនាប្រោសសព្វសត្វ               មិនកំណត់ថាសត្វណា ។
**ទី៣** ពេលព្រលប់                  ព្រះចមភពត្រៃលោកា
ប្រទានធម៌ទេសនា                    ឱ្យឱវាទភិក្ខុសង្ឃ ។
**ទី៤** ពេលអាធ្រាត                 ព្រះលោកនាថទ្រង់ផ្ចិតផ្ចង់
ព្រះទ័យល្អស្មោះត្រង់                ទ្រង់ដោះស្រាយនូវប្រស្នា ។
ផ្សេងៗកើតឡើងពិត                  នៅក្នុងចិត្តនៃទេវតា
ឿងឆ្ងល់ធម៌ត្រង់ណា                 ព្រះសាស្ដាទ្រង់អារកាត់ ។
**ទី៥** ពេលទៀបភ្លឺ                  ប្រមើលមើលនិស្ស័យសត្វ
នៅក្នុងសង្សារវដ្ដ                    ឱ្យប្រាកដគួរសន្ដោស ។
សត្វណាមានសំណាង                 ព្រះអង្គយាងចេញទៅប្រោស
ប្រទានធម៌ទាបខ្ពស់                  ឱ្យទៅតាមឧបនិស្ស័យ ។
ធម៌នេះឈ្មោះហៅថា                  ពុទ្ធក្រិត្យាប្រសើរក្រៃ

វិជ្ជាទិវថ្លៃ នៃព្រះពុទ្ធពីបុរាណ ។
បំពេញឥតនឿយណាយ រៀងរាល់ថ្ងៃមិនដែលខាន
លុះព្រះចូលនិព្វាន ទើបឈប់ខានទាំងអស់ហោង ។
ហៃសាធុជនណា អ្នកប្រាថ្នានឹងប៉ុនប៉ង
ចង់ឃ្លាតពីចំណង ត្រៃលោកនេះពិតប្រាកដ ។
ត្រូវខំរៀនសិក្សា នូវធម៌អាថិ៍ដែលជាបទ
ពុទ្ធកិច្ចប្រាំប្រាកដ នេះកំណត់គួរយល់ដឹង ។
ជននោះនឹងស្មើបាន នឹងនាឋានជាទីពឹង
ឬនៅនាលោកហ្នឹង នឹងបានខ្លួនជាអ្នកធំ ។
លើសជនផងទាំងឡាយ សុខសប្បាយដ៏ឧត្ដម
ក្សេមក្សាន្តសុខមនោរម្យ រៀងរួចដល់និព្វានហោង ។

## ធម្មនិយាម ៣០ របស់ព្រះសម្មាសម្ពុទ្ធគ្រប់ៗអង្គ

សូមក្រាបបង្គំ ប្រណម្យវន្ទា ឆ្ពោះព្រះភគវា ពុទ្ធាបានត្រាស់
ធម្មនិយាម ទំនៀមល្អល្អះ សាមសិបមុខច្បាស់ ខ្ញុំសូមពណ៌នា ។
**មួយ** វញ្ជួយភព ជាតិគ្រប់ចុងក្រោយ បារមីនាំឱ្យ ដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា ដឹងខ្លួនគ្រប់គ្រា ក្នុងគភ៌មាតា ។
**ពីរ** គឺព្រះភគ្គ្រ វរលក្ខណ៍ក្នុងគភ៌ ស្ងឹងស្ងាធ៌ក្នុងធម៌ បវរកាយា

ព្រះភក្ត្របែរផ្ទុយ ពីខ្នងមាតា ឆ្ពោះផ្ទៃភ្លឺថ្លា មាតារំពៃ ។
**បី** តិរិយាបថ នៃព្រះមាតា ពេលគ្រប់មាសា សាស្ដាចាកផ្ទៃ
មាតាទ្រង់ឈរ ខុសស្រីដទៃ ប្រសូតបុត្រថ្លៃ ហឫទ័យជ្រះថ្លា ។
**បួន** សួនឧទ្យាន ទីឋានប្រសូត ក្នុងព្រៃរហូត ឈើស្រូតចេញផ្កា
ទេវតានិងមនុស្ស ថ្វាយសាធុការ ចក្រវាឡបព្វតា ខ្ទររខ្ទារអ៊ូអរ ។
**ប្រាំ** ព្រះប្រសូត ចុះស្រួតយាងឈាន ប្រាំពីរជំហាន ឆ្ពោះទិសឧត្តរ
ត្រួតត្រប់ ទិសឋាន ក្លាហានបវរ ទើបបានបន្ល បន្លឺសីហនាទ ។
**ប្រាំមួយ** ប្រមើល ទតមើលនិមិត្ត ទេវទូតបួនពិត ចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណា ថ្ងៃនោះទ្រង់ឃ្លាត ចិត្តឥតរវាត យាត្រាសាងផ្នួស ។
**ប្រាំពីរ** ធីរោ ផ្ដាច់ប្ដូរព្យាយាម ឥតមានទាក់ទាម ក្នុងនាមអ្នកបួស
កំណត់វេលា មិនអាចតិចហួស ប្រាំពីរថ្ងៃនោះ នឹងបានត្រាស់ដឹង ។
**ប្រាំបី** មហេសី គង់សោយបាយាស ក្នុងថ្ងៃបានត្រាស់ ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹងបានបុណ្យមហិមា ។
**ប្រាំបួន** ជូនភ័ព្វ ទ្រង់ទ្រាប់ស្បូវភ្លាំង ក្លាយជាបល្ល័ង្ក គង់តាំងភាវនា
នៅគល់ពោធិព្រឹក្ស នាទិសបូពា បល្ល័ង្កភគវា ផុសគ្រាសាយ័ណ្ហ ។
**ដប់** គាប់ហឫទ័យ អានាបាណៈ បរិកម្មប្រចក្ស សតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនភាន់ ដំណើរជវន័ ជាន់ឆ្លងកាមា ។
**ដប់មួយ** ជំនួយពី ព្រះបារមី ផ្ចាញ់មារអប្រិយ៍ ព្រមទាំងសេនា

ពុទ្ធប្បវត្តិ ត្រង់នេះអស្ចារ្យ បរិស័ទជ្រះថ្លា បាចផ្កាអភិសេក ។

**ដប់ពីរ** មុនីអង្គ ទ្រង់សម្រេចញាណ ត្រៃវិជ្ជាមាន ទ្រង់ញាណអនេក

ពិសាខបុណ្ណមី កើតញាណប្លែកៗ ពោធិញ្ញាណខ្ពស់ឯក កក្រើកធរណី ។

**ដប់បី** ក្សត្រថ្លៃ គង់ក្នុងមហាឋាន វិមុត្តិក្សេមក្សាន្ត អស់ឋានប្រាំពីរ

សប្ដាហ៍ឋានមួយ លើកសួយស្ថានទី ចេតិយព្រះមុនី ប្រាំពីរកន្លែង ។

**ដប់បួន** ជូនព្រហ្ម ជុំអារាធនា សូមព្រះភគវា យាងត្រាស់សម្ដែង

ព្រះធម៌ប្រពៃ វិស័យសួរសែង ទ្រង់ព្រមសម្ដែង ដោយព្រហ្មវិហារ ។

**ដប់ប្រាំ** ចាំច្បាស់ ទ្រង់ត្រាស់ធម្មចក្រ ឥសិបតនៈព្រៃមិគទាយា

ឋានត្រៃរតនៈអាសាឡ្ហបូជា ថ្ងៃព្រះភគវា ស្ថាបនាព្រះសង្ឃ ។

**ដប់ប្រាំមួយ** ទ្រង់គង់ត្រាស់ឱវាទ បាតិមោក្ខស្អាងស្អាត ឱវាទផ្លូវផង

បេះដូងព្រះធម៌ ពន្លឺចតុរង្គ ថ្ងៃនោះត្រូវត្រង់ មាឃបុណ្ណមី ។

**ដប់ប្រាំពីរ** ទ្រង់គង់វត្តជេតពន ប្រោសដល់មហាជន និរន្ដរ៍ប្រក្រតី

ទ្រង់យកអរុណ ជេតពនសួស្ដី ជេតពនជិនស្រី អាស្រ័យជានិច្ច ។

**ដប់ប្រាំបី** ទ្រង់សម្ដែងបាដិហារ្យ យមកៈអស្ចារ្យនិគ្រន្ថរត់គេច

នៅក្រុងសាវត្ថី ប្រុសស្រីមិនតិច នេះគឺពុទ្ធកិច្ច សង្គ្រោះលោកា ។

**ដប់ប្រាំបួន** ទ្រង់គង់ឋានត្រៃត្រិង្ស ត្រិះរិះរំពឹង ថ្លឹងគុណមាតា

សម្ដែងអភិធម្ម ស័ក្ដិសមអស្ចារ្យ ថ្វាយព្រះមាតា សុខាអមតៈ ។

**ម្ភៃ** គឺព្រះអង្គ ទ្រង់ចាកទេវលោក ស្ដេចយាងចុះមក ដែនសង្កស្សៈ

មហាជនច្រើនពិត យកចិត្តទុកដាក់ បូជាគារវៈអចលចេតិយ ។
**ថ្ងៃមួយ** គឺទ្រង់គង់ក្នុងសមាបត្តិ ព្រះញាណស្ងប់ស្ងាត់លះកាត់លោកិយ៍
អរហត្តផល តម្កល់ប្រក្រតី ឆាប់ក្តីយូរក្តី វិស័យពុទ្ធញាណ ។
**ថ្ងៃពីរ** ប្រមើលមើលគ្រប់វេនេយ្យ ឧបនិស្ស័យ សព្វសត្វដែលមាន
ដោយព្រះករុណា សមាបត្តិញាណ ត្រួតសត្វកោដិលាន មានពីរវារៈ ។
**ថ្ងៃបី** ទ្រង់លៃ វិន័យអាជ្ញា បញ្ញត្តិសិក្ខា តាមការជ្រាបជាក់
មានរឿងកើតមុន ខូចគុណសាវ័ក មានហេតុជាក់លាក់ ទើបដាក់វិន័យ ។
**ថ្ងៃបួន** អង្រួន ហឫទ័យករុណា ជាតកទេសនា សាស្តាលកលៃ
ដើមរឿងជាហេតុ បង្កើតអត្ថន័យ ជាតកប្រពៃលៃតាមហេតុការណ៍ ។
**ថ្ងៃប្រាំ** ទ្រង់ប្រោស ដល់ពួកព្រះញាតិ អង្គព្រះលោកនាថសម្តែងបាដិហារ្យ
កម្ចាត់មានះ ព្រះញាតិវង្សា ទើបត្រាស់ទេសនា គម្ពីរពុទ្ធវង្ស ។
**ថ្ងៃប្រាំមួយ** ទ្រង់គង់ធ្ងន់ក្នុងធមិ បរិស័ទណាល្អ មានធមិទ្រទ្រង់
ស្តេចយាងទទួល ស្រុះស្រួលដោយអង្គ គារវៈផូរផង់ឆ្ពោះត្រង់ព្រះធមិ ។
**ថ្ងៃប្រាំពីរ** ទ្រង់គង់ចាំវស្សា បើមាននរណា និមន្តដោយល្អ
ពេលចេញវស្សា មុនយាងចេញចរ ទ្រង់ចម្រើនពរ ត្រាស់លាអ្នកនោះ ។
**ថ្ងៃប្រាំបី** ទ្រង់គង់យ៉ាងហ្មត់ចត់ មុនភត្តក្រោយភត្ត គ្មានភ្លាត់ភ្លេចសោះ
បំពេញពុទ្ធកិច្ច គ្រប់យាមទាំងអស់ ពុទ្ធកិច្ចសង្គ្រោះ មនុស្សនិងទេវតា ។
**ថ្ងៃប្រាំបួន** ទ្រង់សោយមំសៈ ក្នុងថ្ងៃទ្រង់ដាក់ អនុដ្ឋានកាយា

បិណ្ឌបាតចុងក្រោយជាទានថ្លៃថ្លា  សោយរសមំសា ហប្ចទ័យបរិសុទ្ធ ។
**សាមសិប** អរវិសានទ្រង់បានចូលឈាន  មុននឹងនិព្វាន ឈានច្រើនបំផុត
ម្ភៃប្អូនសែនកោដិ សមាបត្តិបរិសុទ្ធ  រួចហើយទ្រង់ផុត រលត់សង្ខារ ។
✪ **អហំ** វីខ្ញុំបង្គំ វន្ទា  ឆ្ពោះព្រះភគវា ព្រះធម៌ថ្លៃថ្លា
ព្រមទាំងព្រះសង្ឃ ផូរផង់សីលា  ចិន្តាលំអុត ព្រះពុទ្ធនិយាម ។
សូមឱ្យសព្វសត្វ បដិបត្តិតាមធម៌  សាសនាបវរ ល្អដូចព្រះនាម
អរហំសម្មា គ្មានការទាក់ទាម  កិលេសរវាម រវាតសូន្យបង់ ។
សូមឱ្យសាសនា សម្មាសម្ពុទ្ធ  បរិស័ទមោះមុត រួមចិត្តទ្រទ្រង់
ឋិតថេរចិរកាល អភិបាលដោយសង្ឃ  ព្រមព្រៀងស្មោះត្រង់ ផ្ចិតផ្ចង់សិក្ខា ។
សូមមនុស្ស ទេវតា មានការគោរព  ទាំងថ្ងៃទាំងយប់ ក្នុងព្រះសាសនា
សូមបានសម្រេច ដូចក្តីប្រាថ្នា  អស់នូវតណ្ហា ទុក្ខាចប់ហោង ។

# ការក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ
## (តាំង នមោ ៣ ចប់)

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះអរិយសង្ឃ ជាទីពឹងទីរលឹក។ ខ្ញុំព្រះករុណា សូមក្រាបនមស្ការបូជាព្រះគុណ នៃអង្គព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ពេញពោរទៅដោយព្រះមេត្តាករុណា រកប្រមាណមិនបាន។ ព្រះអង្គទ្រង់លះបង់គ្រប់យ៉ាងក្នុងការសន្សំព្រះបារមីដើម្បីត្រាស់ដឹង ហើយប្រកាសធម៌ នាំវេនេយ្យសត្វចេញចាកពីវដ្តៈ។ ខ្ញុំព្រះករុណាបូជាព្រះពុទ្ធចេតិយដោយសេចក្តីជ្រះថ្លាដ៏ក្រៃលែង សូមតាំងសច្ចាធិដ្ឋាន ដោយផលានិសង្សនៃបុណ្យ ដែលខ្ញុំព្រះករុណាបានធ្វើក្នុងថ្ងៃនេះ សូមជាបច្ច័យឱ្យបានសម្រេច ដូចសេចក្តីប្រាថ្នា ។ អង្គព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងធម៌យ៉ាងណា សូមអោយខ្ញុំព្រះករុណាមានចំណែកនៃធម៌របស់ព្រះអង្គក្នុងកាលដ៏សមគួរផងចុះ។ ទោះបីកើតក្នុងភពជាតិណាៗ សូមកើតនៅក្រោមម្លប់នៃបវរព្រះពុទ្ធសាសនា កណ្តាលកល្យាណមិត្ត បានសេពគប់នឹងសប្បុរសធម៌ ដែលជាអ្នកដឹងនូវធម៌ដ៏ប្រសើរ សូមជាបុគ្គលសម្មាទិដ្ឋិមានឱកាសសិក្សាធម៌ ស្តាប់ធម៌ ប្រព្រឹត្តធម៌ ដែលជាបច្ច័យឱ្យចម្រើនទៅដោយសតិ និងបញ្ញាបញ្ជូនតទៅគ្រប់ជាតិ រហូតដល់ព្រះនិព្វានហោង ។

ចម្លងចេញអំពីបូជនីយដ្ឋានព្រះពោធិព្រឹក្ស ព្រះពុទ្ធ ២៨ អង្គ
(ថ្ងៃសុក្រ ១៥ កើត ខែអស្សុជ ឆ្នាំកុរ នព្វស័ក ព. ស. ២៥៥១)

# ធម៌សម្រាប់ស្រូចទឹកស្លោនក់

**ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា**

( អិមិណា ប៊ុញញ៉ាក់កាំមេនាក់ អ៊ុប៉ាច់ឈាយា គុណុតតាក់រ៉ា)

**អាចរិយូបការា ច មាតាបិតា (ច ញាតិកា)**

( អាចាក៊ិរុយ៉ូប៉ាក់ការ៉ា ចាក់ មាតាប៊ុតា ( ចាក់ ញ៉ាតិកា)

**បិយាមមំ សុរិយោ ចន្ទិមា រាជា គុណវន្តា**

( ប៊ិយាមាក់មាំង សុរិយោ៉ ចាន់ទិមា រាជា គុណាក់វ៉ាន់តា)

**នរាបិ ច ព្រហ្មា មារា ច ឥន្ទ្រា ច លោកបាលា**

( នាក់រាប៊ិ ចាក់ ព្រាំមា មារា ចាក់ អ៊ិនទ្រា ចាក់ លោកាក់ប៉ាឡា)

**ច ទេវតា យមោ មិត្តា មនុស្សា ច មជ្ឈត្តា**

( ចាក់ ទេវ៉ាក់តា  យ៉ាក់មោ មិតតា មាក់នុសសា ចាក់  មាច់ឈាត់តា)

**វេរិកាបិ ច សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ**

( វេរិកាប៊ិ ចាក់ សាប់ពេ សាត់តា សុខី ហោនតុ ប៊ុញញ៉ានិ)

**បកតានិ មេ សុខញ្ច តិវិធំ ទេន្តុ ខិប្បំ**

( ប៉ាក់កាក់តានិ មេ សុខាញ់ចាក់ តិវិធាំង ទេនតុ ខិបប៉ុំង)

**ឃាបេថ វោមតំ ២** ប៉ាប៉េថាក់ វោមាក់តាំង)

**ប្រែថា** ដោយបុញ្ញកម្មនេះ ឧបជ្ឈាយ៍ទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់

អាចារ្យទាំងឡាយ មានឧបការៈ មាតាបិតាជាទីស្រឡាញ់នៃខ្ញុំ ព្រះអាទិត្យ ព្រះចន្ទ្រ រាជការ នរជនអ្នកមានគុណទាំងឡាយ ព្រះព្រហ្ម មារាធិរាជ ព្រះឥន្ទ ទាំងឡាយ លោកបាលមហារាជ និងទេវតាទាំងឡាយ ព្រះយមរាជ និងមនុស្ស ទាំងឡាយ ជាមិត្តនឹងគ្នាក្តី មានចិត្តជាកណ្តាលក្តី មានពៀរជាមួយគ្នាក្តី (រួបរួមសេចក្តីថា) សូមឱ្យសព្វសត្វទាំងឡាយ មានសេចក្តីសុខរាល់គ្នា បុណ្យ ទាំងឡាយ ដែលខ្ញុំបាន កសាងសន្សំហើយ ចូរឱ្យនូវសេចក្តីសុខទាំង ៣ ប្រការ សូមឱ្យអ្នកទាំងឡាយ បានដល់នូវអមតមហានិព្វាន ឱ្យបានឆាប់រួសរាន់ទាន់ សេចក្តីប្រាថ្នាហោង ។

**ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច**

(អិមិណា ប៉ុញញ៉ាក់កាំមេនាក់ អិមិណា អ៊ុទទិសេនាក់ ចាក់)

**ខិប្បាហំ សុលភេចេវ តណ្ហុប្បាទាន~**

(ខិបប៉ាហាំង សុឡាក់ភេចេវ៉ាក់ តាន់ហុបប៉ាទានាក់)

**ឆេទនំ យេ សន្តានេ ហីនាធម្មា យាវ និព្វានតោ**

(ឆេទាក់ណាំង យេ សាន់តានេ ហីណាធ័មមា យាវ៉ាក់ និពពានាក់តោ)

**មមំ នស្សន្តុ សព្វទាយេវ យត្ថ ជាតោ**

(មាក់មាំង នាស់សាន់តុ សាប់ពាក់ទាយេវ៉ាក់ យាត់ថាក់ ជាតោ)

**ភវាភវេ ឧជុំចិត្តោ សតិប្បញ្ញោ សល្លេខោ**

(ភាក់វាភាក់វេ អ៊ុជុចិតតោ សាក់តិបប៉ាញ់ញ៉ោ សាល់ឡេខោ)

**វីរិយោម្ហិ វា មារា លភន្តុ នោ ការសំ ការតុញ្ញ**

(វីរិយោម្ហិ វា មារា លាក់ភាន់តុ នោ កាសាំង កាតុញ្ញចាក់)

**វីរិយេ សុមេ ពុទ្ធោ ទីបវរោ នាថោ ធម្មោ នាថោ**

(វីរិយេ សុមេ ពុទធោ ទីប៉ាក់វាក់រោ នាថោ ធ័មមោ នាថោ)

**វរុត្តមោ នាថោ បច្ចេកពុទ្ធោ ច សង្ឃោ**

(វាក់រុតតាក់ម៉ោ នាថោ ប៉ាច់ចេកាក់ពុទធោ ចាក់ សាំងឃោ)

**នាថោត្តរោ មមំ តេ សោត្តមានុភាវេន**

(នាថោតតាក់រ៉ោ មាក់មាំង តេ សោតតាក់ម៉ានុភាវេនាក់)

**មារោ ការសំ លភន្តុ មា ៗ** (មារោ កាសាំង លាក់ភាន់តុ មា)

**ប្រែថា** ដោយបុញ្ញកម្មនេះផង ដោយការឧទ្ទិសនេះផង សូមឱ្យខ្ញុំបាន ដោយងាយយ៉ាងរួសរាន់ទាន់ចិត្ត នូវមគ្គផលជាគ្រឿងផ្តាច់បង់នូវតណ្ហា និងឧបាទានធម៌ទាំងឡាយណា ជាធម៌ថោកទាប ជាអកុសលធម៌ គឺអកុសលធម៌នៅក្នុងសន្តានចិត្តខ្ញុំ (ហើនធម៌ជាធម៌អកុសលទាំងនោះ) វិនាសបាត់រៀងរាល់កាលទៅ រហូតដល់ខ្ញុំបានសម្រេចព្រះនិព្វាន (ក្នុងបច្ឆិមជាតិ)(បើ) ខ្ញុំអន្ទោលទៅចាប់កំណើតក្នុងភពតូច និងភពធំណាៗ សូមឱ្យខ្ញុំជាបុគ្គលមានចិត្តត្រង់មានសតិ និងបញ្ញា មានចិត្តស្អាតផូរផង់ ទាំងសូមឱ្យព្យាយាមផង (ក្នុងភព

នោះ។) មារទាំងឡាយ ចូរកុំបាននូវឱកាស ដើម្បីកុំឱ្យខូចនូវការព្យាយាមខ្ញុំ ព្រះពុទ្ធដូចជាប្រទីប ឬកោះដ៏ប្រសើរ ជាទីពឹងនៃខ្ញុំ ព្រះធម៌ជាទីពឹងដ៏ប្រសើរខ្ពង់ខ្ពស់នៃខ្ញុំ ទាំងព្រះបច្ចេកពុទ្ធ ក៏ជាទីពឹងនៃខ្ញុំផងដែរ ព្រះសង្ឃក៏ជាទីពឹងខ្ពង់ខ្ពស់នៃខ្ញុំដែរ ដោយឧត្តមានុភាពនៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃនោះ មារចូរកុំបានឱកាស ចូលមកជ្រៀតជ្រែកឡើយ ។

## មង្គល ៣៨ ប្រការ

### អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា

( អាក់សេវ៉ាក់ណា ចាក់ ពាលានាំង ប៉ាន់ឌិតាណាញ់ចាក់ សេវ៉ាក់ណា)

### បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។

( ប៉ូជា ចាក់ ប៉ូជាក់នីយាណាំង អេតាំមាំងគាក់លាក់មុតតាក់មុំាង)

**វគ្គទី១** កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

### បដិរូបទេសវាសោ ច បុញ្ញេ ច កតបុញ្ញតា

( ប៉ាក់ដិរូបាក់ទេសាក់វ៉ាសោ ចាក់ ប៉ុពពេ ចាក់ កាក់តាក់ប៉ុញញាក់តា)

### អត្តសម្មាបណិធិ ច ឯតម្មង្គលមុត្តមំ ។

( អាត់តាក់សាំម៉ាប៉ាក់ណើធិ ចាក់ អេតាំមាំងគាក់លាក់មុតតាក់ម៉ាំង)

**វគ្គទី២** កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាតម្កល់ខ្លួនដោយប្រពៃ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

**ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ**

( ពាហុសាច់ចាញ់ចាក់ សិបប៉ាញ់ចាក់ វិនាក់យោ ចាក់ សុសិកខិតោ)

**សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ ។**

(សុភាសិតា ចាក់ យា វាចា អេតាំមាំងគាក់លាក់មុតតាក់ម៉ាំង)

**វគ្គទី៣** ភាវៈនៃបុគ្គលបានស្តាប់បានរៀនហើយដោយច្រើន ១ សិល្បសាស្ត្រ គឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**មាតាបិតុឧបដ្ឋានំ បុត្តទារស្ស សង្គហោ**

( មាតាបិតុអ៊ុប៉ាត់ថាណាំង ប៊ុតតាក់ទារាក់សាក់ សាំងគាក់ហោ)

**អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ ។**

( អាក់ណាកុឡា ចាក់ កាំម៉ាន់តា អេតាំមាំងគាក់លាក់មុតតាក់ម៉ាំង)

**វគ្គទី៤** កិរិយាបម្រើនូវមាតា ១ កិរិយាបម្រើនូវបិតា ១ សេចក្តីសង្គ្រោះ

ដល់បុត្រ និងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ**

( ទាណាញ់ចាក់ ធ័មមាក់ចាក់រិយ៉ា ចាក់ ញាតាក់កាណាញ់ចាក់ សាំងគាក់ហោ)

**អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ ។**

( អាក់នាក់វ៉ាច់ជានិ កាំម៉ានិ អេតាំមាំងគាក់លាក់មុតតាក់មាំង)

**វគ្គទី៥** កិរិយាបរិច្ចាគទាន ១ កិរិយាប្រព្រឹត្តនូវធម៌ ១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ ទាំង៤ នេះជាមង្គលដ៏ឧត្តម ។

**អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ**

( អារ៉ាក់តី វិរ៉ាក់តី ប៉ាប៉ា ម៉ាច់ជាក់ប៉ាណា ចាក់ សាញ់ញ៉ាក់ម៉ោ)

**អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។**

( អាប់ប៉ាក់ម៉ាទោ ចាក់ ធ័មមេសុ អេតាំមាំងគាក់លាក់មុតតាក់មាំង)

**វគ្គទី៦** កិរិយាមិនត្រេកអរក្នុងបាប និង កិរិយាវៀរចាកបាប ១ សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

**គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា**

( គារាក់វោ ចាក់ និវាតោ ចាក់ សាន់តុតថី ចាក់ កាក់តាញ់ញុតា)

## កាលេន ធម្មសវនំ ឯតម្មង្គលមុត្តមំ ។

( កាឡេនាក់ ធ័មមាក់សាក់វ៉ាក់ណាំង អេតាំមាំងគាក់លាក់មុតតាក់ម៉ាំង)

**វគ្គទី៧** សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន ១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន ១ កិរិយាស្តាប់នូវធមិតាមកាល ១ ទាំង ៥ នេះជាមង្គលដ៏ឧត្តម ។

## ខន្តី ច សោវចស្សតា សមណានញ្ច ទស្សនំ

( ខាន់តិ ចាក់ សោវ៉ាក់ចាស់សាក់តា សាក់មាក់ណាណាញ់ចាក់ ទៈសាក់ណាំង)

## កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។

( កាឡេនាក់ ធ័មមាក់សាកាច់ឆា អេតាំមាំងគាក់លាក់មុតតាក់ម៉ាំង)

**វគ្គទី៨** សេចក្តីអត់ធន់១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ ១ ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមក នូវធមិតាមកាល ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

## តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចានទស្សនំ

( តាក់ប៉ោ ចាក់ ព្រាំមាក់ចាក៉ិរិយាញ់ចាក់ អាក៉ិរិយាក់សាច់ចានាក់ទៈសាក់ណាំង)

## និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។

( និបពានាក់សាច់ឆិកិរិយា ចាក់ អេតាំមាំងគាក់លាក់មុតតាក់ម៉ាំង)

**វគ្គទី៩** សេចក្តីព្យាយាមដុតនូវបាបធមិ ១ កិរិយាប្រព្រឹត្តនូវធមិដ៏ប្រសើរ ១

កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**

( ផុតថាស់សាក់ លោកាក់ធ័មមេហិ ចិតតាំង យ៉ាស់សាក់ នាក់ កាំប៉ាក់តិ)

**អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ ។**

( អាក់សោកាំង វិរាក់ជាំង ខេម៉ាំង អេតាំមាំងគាក់លាក់មុតតាក់ម៉ាំង)

**វគ្គទី១០** ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មានធូលី គឺរាគៈទៅប្រាស់ហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា**

( អេតាទិសានិ កាត់ត្វានាក់ សាប់ពាត់ថាក់មាក់ប៉ាក់រ៉ាជិតា)

**សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។**

(សាប់ពាត់ថាក់ សោថឹង គាច់ឆាន់តិ តាន់តេសាំង មាំងគាក់លាក់មុតតាក់ម៉ាន់តិ)

ទេវតា និង មនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះ ហើយជាអ្នកមិនចាល់ចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តីក្នុងទីទាំងពួង( ម្នាលទេវតាអ្នកចូរប្រកាន់ជឿថា) មង្គលទាំង៣៨ប្រការ មានកិរិយាមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតា និងមនុស្សទាំងអម្បាលណោះ ជាមង្គលដ៏ឧត្តម ។

## បរាភវសូត្រ

❋❋❋✻❋❋❋

(បទបឋ្យាវត្ត)

**បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ**

( ប៉ាក់រ៉ាភាក់វ៉ាន់តាំង ប៊ុរិសាំង ម៉ាក់យាំង ប៉ុចឆាមាក់ គោតាក់មុាំង)

**ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។**

( ភាក់វ៉ាន់តាំង ប៉ុដថុម៉ាគាំមាក់ កឹង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ មកសូមទូលសួរ នូវហេតុដែលគួរ ចម្រើនវិនាស
ប្រុសស្រីក្នុងលោកសន្និវាស ដែលនឹងវិនាស សាបសូន្យចាកគុណ ។
ឱ្ពោះព្រះគោតម ព្រះអង្គមានបុណ្យ មេត្តានិមន្ត សម្តែងឱ្យទាន
ធម្មជាតិដូចម្តេច ដែលជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

*(ព្រះសាស្តា ឆ្លើយតបនឹងទេវតាថា)*

**សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ**

( សុវិចជានោ ភាក់វាំង ហោតិ សុវិចជានោ ប៉ាក់រ៉ាភាក់វោ)

**ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។**

( ធ័មមាក់កាមោ ភាក់វាំង ហោតិ ធ័មមាក់ទេសសី ប៉ាក់រ៉ាភាក់វោ)

អ្នកដែលចម្រើន តថាគតស្គាល់ងាយ អ្នកដែលអន្តរាយ តថាគតស្គាល់ពិត
អ្នកប្រាថ្នាធម៌ ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្ត នឹងបានចម្រើន។
អ្នកដែលទ្រុស្តធម៌ ស្អប់ធម៌ឥតកើន ឥតកើតចម្រើន វិនាសទៅមុខ ។

**ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ**

( ឥតិ ហេតាំង វិជានាមាក់ ប៉ាក់ថាក់ម៉ោ សោ ប៉ាក់រ៉ាភាក់វ៉ោ)

**ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

( ទុតិយាំង ភាក់គាក់វ៉ា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ១ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ២ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**អសន្តស្ស បិយោ ហោតិ សន្តេន ក្រុតេ បិយំ**

( អាក់សាន់តាស់សាក់ ប៉ិយោ៉ ហោតិ សាន់តេនាក់ កុរុតេ បិយាំង)

**អសតំ ធម្មរោចេតិ តំ បរាភវតោ មុខំ ។**

( អាក់សាក់តាំង ធ័មមាក់រោចេតិ តាំង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា តែនឹងមនុស្សណា អសប្បុរស

តែងមិនស្រឡាញ់ ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរស មកធ្វើជាមិត្ត
សេចក្តីស្រឡាញ់ ពេញចិត្តគំនិត ហើយទៅគប់មិត្ត អសប្បុរស
គាប់ចិត្តក្នុងធម៌ ឬមួយរបស់ ហេតុនោះទាំងអស់ នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ**

( អ៊ិតិ ហេតាំង វិជានាមាក់ ទុតិយោ សោ ប៉ាក់រ៉ាភាក់វ៉ោ)

**តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ៕**

( តាក់តិយ៉ាំង ភាក់គាក់វ៉ា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ២ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ៣ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ**

( និទទាសីឡី សាក់ភាសីឡី អាក់នុតថាតា ចាក់ យោ នាក់រោ)

**អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ៕**

( អាក់លាក់សោ កោធាក់ប៉ាញ់ញ៉ាណោ តាំង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

អ្នកដេកច្រើនមួយ និយាយច្រើនមួយ និងអ្នកឥតព្រួយ ឥតគិតប្រឹងប្រែង

អ្នកខ្ជិលច្រអូស មិនមានខ្នះខ្នែង ខឹងច្រើនសម្តែង ឱ្យគេឃើញបាន ហេតុធមិទាំងនោះ មិនជាកល្យាណ នាំឱ្យខកខាន ខាតខូចប្រយោជន៍ មានជាប្រធាន តិចច្រើនដោយហោច នាំបង់ប្រយោជន៍ ហើយឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ**

( អ៊ិតិ ហេតាំង វិជានាមាក់ តាក់តិយ៉ោ សោ ប៉ាក់រ៉ាភាក់វ៉ោ)

**ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

( ចាក់តុតថាំង ភាក់គាក់វ៉ា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៣ ទាន់ហន់ ។ បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន វិនាសទី ៤ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ**

( យោ មាតាក់រ៉ាំង វ៉ា ប៊ិតាក់រ៉ាំង វ៉ា ជិនណាក់កាំង គាក់តាក់យោពាក់ណាំង)

**បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។**

( ប៉ាក់ហុសាន់តោ នាក់ ភាក់រាក់តិ តាំង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

នរជនណា មានទ្រព្យធនធាន ហើយខ្លួនមិនបាន ចិញ្ចឹមរក្សា

មាតាបិតា ដែលចាស់ជរា ហេតុនោះទៅជា នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ**

( អ៊ិតិ ហេតាំង វិជានាមាក់ ចាក់តុតថោ សោ ប៉ាក់រ៉ាភាក់វោ)

**បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

( ប៉ាញ់ចាក់ម៉ាំង ភាក់គាក់វ៉ា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៤ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន វិនាសទី ៥ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**យោ ព្រាហ្មណំ សមណំ វា អញ្ញំ វាបិ វនិព្វកំ**

(យោ ព្រាមមាក់ណាំង សាក់មាក់ណាំង វ៉ា អាញ់ញ៉ាំង វ៉ាប៊ិ វ៉ាក់និពពាក់កាំង)

**មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។**

( មុសាវ៉ាទេនាក់ វ៉ាញ់ចេតិ តាំង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

ជនបញ្ឆោតព្រាហ្មណ៍ ឬពួកសមណៈ ពួកស្មូមឬអ្នក ដទៃៗ ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ នោះប្រធាននៃ សេក្តីវិនាស

**ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ**

( អុិតិ ហេតាំង វិជានាមាក់ ប៉ាញ់ចាក់ម៉ោ សោ ប៉ាក់រ៉ាភាក់វោ)

**ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

( ឆាត់ថាក់មាំង ភាក់គាក់វា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ  បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ  បើរាប់សង្គ្រោះ  វិនាសនោះឈ្មោះ  ទី ៥ ទាន់ហន់ ។

បពិត្រព្រះអង្គ  ព្រះនាមភគវន្ត  សូមទ្រង់និមន្ត  សម្តែងឱ្យទាន

វិនាសទី ៦  អ្វីជាប្រធាន  នាំសត្វឱ្យមាន  សេចក្តីវិនាស ។

**បហូតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ**

( ប៉ាក់ហុតាក់វិតតោ ប៉ុរិសោ សាក់ហិរ៉ាញ់ញោ សាក់ភោជាក់នោ)

**ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។**

( អេកោ ភុញជាក់តិ សាទូនិ តាំង ប៉ាក់រ៉ាភាក់វាក់តោ មុខាំង)

បុរសអ្នកមាន  ទ្រព្យធនធានច្រើន មាសប្រាក់ចម្រើន និងគ្រឿងអាហារ

លបលាក់របស់  ដែលឆ្ងាញ់ពិសារ  ស៊ីម្នាក់ឯងជា  ប្រធានវិនាស ។

**ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ**

( អុិតិ ហេតាំង វិជានាមាក់ ឆាត់ថាក់ម៉ោ សោ ប៉ាក់រាភាក់វោ)

**សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

(សាត់តាក់មុំាង ភាក់គាក់វ៉ា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនោះឯង ព្រោះហេតុដូច្នោះ

ក្ដីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៦ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឱ្យទាន

វិនាសទី ៧ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្ដីវិនាស ។

**ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ**

(ជាតិតថាត់ធោ ធាក់ណាត់ថាត់ធោ គោតតាត់ថាត់ធោ ចាក់ យោ នាក់រោ)

**សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។**

(សាញ់ញ៉ាតឹង អាក់តិម៉ាញញេតិ តាំង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកូល ហើយមិនប្រមូល សាច់ញាតិសន្ដាន

មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន នោះជាប្រធាន សេចក្ដីវិនាស ។

**ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ**

(អ៊ិតិ ហេតាងំ វិជានាមាក់ សាត់តាក់ម៉ោ សោ ប៉ាក់រ៉ាភាក់វ៉ោ)

**អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

(អាត់ថាក់មាំុង ភាក់គាក់វ៉ា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ  បានដឹងជាក់ស្ដែង វិនាសនោះឯង  ព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះ   បើរាប់សង្គ្រោះ   វិនាសនោះឈ្មោះ   ទី ៧ ទាន់ហន់ ។

បពិត្រព្រះអង្គ   ព្រះនាមភគវន្ត   សូមទ្រង់និមន្ត   សម្ដែងឱ្យទាន
វិនាសទី ៨   អ្វីជាប្រធាន   នាំសត្វឱ្យមាន   សេចក្ដីវិនាស ។

**ឥត្ថីធុត្តោ  សុរាធុត្តោ   អក្ខធុត្តោ  ច  យោ  នរោ**

(អិតថីធុតតោ សុរាធុតតោ អាក់ខាក់ធុតតោ ចាក់ យោ នាក់រោ)

**លទ្ធំ  លទ្ធំ  វិនាសេតិ   តំ  បរាភវតោ  មុខំ  ។**

(លាត់ធាំង លាត់ធាំង វិនាសេតិ  តាំង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

ជនអ្នកប្រព្រឹត្ត  ល្បែងបីប្រការ ល្បែងស្រីល្បែងស្រា ល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមាន   ឱ្យអន្ដរាយ   ការល្បែងទាំងឡាយ  នោះនាំវិនាស ។

**ឥតិ  ហេតំ  វិជានាម  អដ្ឋមោ  សោ  បរាភវោ**

(ឥតិ ហេតាំង វិជានាមាក់ អាត់ថាក់ម៉ោ សោ ប៉ាក់រ៉ាភាក់វ៉ោ)

**នវមំ  ភគវា  ព្រូហិ  កឹ  បរាភវតោ  មុខំ  ។**

(នាក់វ៉ាក់មាំង ភាក់គាក់វ៉ា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ   បានដឹងជាក់ស្ដែង វិនាសនោះឯង ព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះ  បើរាប់សង្គ្រោះ   វិនាសនោះឈ្មោះ   ទី ៨ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ៩ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ**

(សេហិ ទារេហិ អាក់សាន់តុតថោ វេសិយាសុ ប៉ាក់ទុសសាក់តិ)

**ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ៕**

(ទុសសាក់តិ ប៉ាក់រ៉ាក់ទារេសុ តាំង ប៉ាក់រ៉ាភាក់វតោ មុខាំង)

ប្រុសមិនត្រេកអរ និងប្រពន្ធខ្លួន ហើយទៅគាប់ជួន នឹងស្រីពេស្យា
ទ្រុស្តនិងប្រពន្ធ កូនជននានា ហេតុនោះទៅជា នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម នវមោ សោ បរាភវោ**

(អិតិ ហេតាំង វិជានាមាក់ នាក់វាក់មោ សោ ប៉ាក់រ៉ាភាក់វោ)

**ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ៕**

(ទាក់សាក់មាំង ភាក់គាក់វា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ៩ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ១០ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ**

( អាក់តីតាក់យោប់ពាក់នោ ប៉ោសោ អានេតិ តឹមភាក់រុតថាក់នឹង)

**តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។**

( តាស់សា អ៊ិសសា នាក់ សុប៉ាក់តិ តាំង ប៉ាក់រ៉ាភាក់វាក់តោ មុខាំង)

បុរសមានវ័យ ដែលចាស់ហួសពេក ហើយមានតម្រេក ដោយក្តីតណ្ហា

នាំយកស្រីក្មេង មកធ្វើភរិយា ហេតុនោះទៅជា នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ទសមោ សោ បរាភវោ**

( អ៊ិតិ ហេតាំង វិជានាមាក់ ទាក់សាក់ម៉ោ សោ ប៉ាក់រ៉ាភាក់វៅ)

**ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

( អេកាទាក់សាក់មុាំង ភាក់គាក់វា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ១០ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី ១១ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**ឥត្ថី សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ**

( អ៊ិតថី សោនឌឹង វិកិរ៉ាក់ណឹង ប៉ុរ៉ិសាំង វាបិ តាទិសាំង)

**ឥស្សរិយស្មឹំ ឋបេតិ តំ បរាភវតោ មុខំ ។**

( អ៊ិសសាក៉រិយាក់ស្មឹង ថាក់ប៉េតិ តាំង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

បុរសតាំងស្រី អ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយ តាំងបុរសនោះ

ដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះ នាំឱ្យវិនាស ។

**ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ**

( អ៊ិតិ ហេតាំង វិជានាមាក់ អេកាទាក់សាក់ម៉ោ សោ ប៉ាក់រ៉ាភាក់វ៉ោ)

**ទ្វាទសមំ ភគវា ព្រូហិ កឹំ បរាភវតោ មុខំ ។**

( ទ្វាទាក់សាក់មាំង ភាក់គាក់វ៉ា ព្រូហិ កឹង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង ព្រោះហេតុដូច្នោះ

ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី ១១ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី ១២ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

**អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ**

( អាប់ប៉ាក់ភោគោ មាក់ហាតាន់ហោ ខាត់តិយេ ជាយាក់តេ កុលេ)

**សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។**

( សោ ចាក់ រាច់ជាំង ប៉ាត់ថាក់យាក់តិ តាំង ប៉ាក់រ៉ាភាក់វ៉ាក់តោ មុខាំង)

ជនណាកើតក្នុង ត្រកូលជាក្សត្រ អ្នកខ្សត់សម្បត្តិ ហើយប្រាថ្នាធំ
ចង់បានជាស្តេច សោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំ ឱ្យដល់វិនាស ។

**ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ**

(អេតេ ប៉ាក់រ៉ាភាក់វេ លោកេ ប៉ាន់ឌិតោ សាក់មាក់វេកខិយាក់)

**អរិយទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ៕**

(អាក៊ិរិយក្សទះសាក់នាក់សាំប៉ាន់ណោ សាក់ លោកាំង ភាក់ជាក់តេ សិវ៉ាំង)

ជនជាបណ្ឌិត គំនិតប្រសើរ បានឃើញដំណើរ នៃហេតុវិនាស
ដល់សត្វក្នុងលោ- កសន្និវាស គេចពីវិនាស គប់រកចម្រើន ។



# គុណកែវទាំងបី

ព្រះរតនត្រ័យ វិសេសថ្លៃបីប្រការ ដែលមនុស្សនិងទេព្តា
តែងបូជាគ្រប់ទីឋាន។
ទី១ព្រះសម្ពុទ្ធ បញ្ញាមុតអនន្តញាណ ព្រះធម៌ទុកដូចជាយាន
នាំសត្វបានជាទីពីរ។
ព្រះសង្ឃបរិសុទ្ធ វិសាលផុតស្ងប់ឥន្ទ្រីយ៍ ជួយអង្គព្រះមុនី
គ្រប់ទិសទីជាទីបី ។
អ្នកដល់រតនត្រ័យ ផុតទុក្ខភ័យមានសិរី ចាប់តាំងពីលោកិយ
រៀងដរាបដល់និព្វន។
កុំគប្បីប្រមាទ ត្រូវសង្វាតខំសូត្ររៀន ធម៌អាថ៌ព្រះទ្រង់ញាណ
កុំបីខានគ្រប់ៗគ្នា ។
នាំគ្នាបដិបត្តិ រៀងរាល់រត្តិទិវា ជោគជ័យសិរីសុខា
ឈ្នះមារាគ្រប់គ្នាហោង ។